Free
សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

REMEDIUM PHARMACY
ឱសថស្ថានរ៉េមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម • ការវេចខ្ចប់ឱសថ • ការលាយផ្សំឱសថ
• បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ • ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

Cambodia Daily
Cambodian Politic

## With Rainsy Out, Sokha Takes Helm at Assembly

by Ben Paviour and KhuonNarim | December 8, 2016

In a move that further marginalized opposition leader Sam Rainsy and threatened to deepen party fissures, Prime Minister Hun Sen said that acting CNRP president KemSokha would replace Mr. Rainsy as his point of contact in the opposition.

The announcement, which occurred just days after King Norodom Sihamoni's pardon of Mr. Sokha in a "prostitution" case at the behest of Mr. Hun Sen, contradicted tweets from the exiled



Mr. Rainsy on Monday saying that he would remain minority leader.

Mr. Hun Sen said on Wednesday that the change in pecking order stemmed from a CNRP request on Monday for Mr. Sokha to replace Mr. Rainsy as head of the "minority group" **Continued toPage 15**

# មេរីគ្រីស្មឹស នឹង រីករាយឆ្នាំថ្មី ឆ្នាំ២០១៧




ពេលនេះជាឱកាសឈប់សម្រាកយ៉ាងវែងនឹងយ៉ាងរីករាយនាចុងឆ្នាំចាស់២០១៦ រហូតចូលឆ្នាំថ្មី ២០១៧។ ប្រជាពលរដ្ឋខ្មែរយើង ក៏ដូចជាសាសន៍ដ៏ទៃដែលរស់នៅជិតខាងយើងបន្ទាប់ពីបានធ្វើការយ៉ាងប្រឹងប្រែងនឹងហត់នឿយអស់ពេលពេញមួយឆ្នាំមកនាំគ្នាប្រារព្ធបុណ្យជួបជុំគ្នាទាំងក្នុងគ្រួសារនឹងជាមួយមិត្តភ័ក្រ្ត។ សូមឱ្យពិធីបុណ្យគ្រីស្តស្មឹសនាំមកនូវអំណោយដ៏គាប់ចិត្តពីព្រះគ្រប់អង្គនឹងប្រកបដោយភាពរីករាយក្នុងគ្រួសារ -សូមឱ្យឆ្នាំថ្មីបន្តនូវភាពរីករាយ មានសុភមង្គលមានសុខភាពល្អ ក្នុងគ្រួសារឱ្យបានគ្រប់គ្រប់គ្នា។ **ពីបុគ្គលិកខ្មែរប៉ុស្ដិ៍ស.រ.អា.**

មាតិការរឿង Issue 215 from. Dec. 22th, 2016 - Jan. 05th, 2017
មានផែនទីក្រុងខ្មែរឡូវែល និងប្រក្រតិទិន នៅទំព័រក្នុង

១-ស្នាដៃថ្មីនៃនយោបាយលោក ហ៊ុន សែន............០៣
២-សុខផល ប៉ែន ទើបនឹងត្រឡប់មកពីកម្ពុជា..........០៤
៣-ការផលិតនឹងប្រើប្រាស់កញ្ឆាឥឡូវបានក្លាយ........០៦
៤-មូលនិធិសហគមន៍ឡូវែលសម្រាប់ផ្ដល់...............១០
៥-ប្រជាជនខ្មែរនិយមទិញទំនិញ និងអាហារ..........២២
៦-រឿងចៅពិន................................................២៤
៧-របៀបធ្វើ គៀវចៀន....................................២៨

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554
ឱសថស្ថានសេនជូរី :
យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!

▸ ផ្ដល់សេវាដល់ទីលំនៅ
▸ ខ្ចប់ឱសថតាមបំណង
▸ ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត
937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476

មេធាវី ល្វីយហាស្កែល
Attorney Louis S. Haskell
978-459-8359
16 Pine Street - Lowell, MA 01851
www.attorneyhaskell.com

របួសរាងកាយ គ្រោះថ្នាក់ចរាចរ
PERSONAL INJURY AUTO ACCIDENTS
យើងនិយាយភាសាខ្មែរ.ឡាវ.ថៃ
អាចណាត់ជួបពេលល្ងាចក៏បាន
មានកន្លែងចតរថយន្តឥតចេញថ្លៃ
មានអាជ្ញាប័ណ្ណនៅរដ្ឋ MA និង NH
បំរើសហគមន៍ខ្មែរតាំងពីឆ្នាំ១៩៨៧
We Speak Khmer, Lao, Thai
Evening Appointments Available
Free Parking
Licensed in MA & NH
Serving the Cambodian Community since 1987

# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជា
ឱសថ
ស្ថានមួយ
ដែលអាចផ្តល់
ភាពជឿជាក់
ដល់គ្រួសារ
លោកអ្នក




យើងខ្ញុំ
សូមជូនពរ
មហាប្រសើរ
ដល់លោក
អ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ែល, និងកាតធានារ៉ាប់រងសុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្ញើថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។ ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

**លេខទូរស័ព្ទ 978-455-6554**

**លេខហ្វាក់ 978-455-9476**

937 Gorham St Lowell, MA, 01852

# ស្នាដៃថ្មីនៃនយោបាយលោក ហ៊ុន សែន

**ដោយ ពិន សំខុន**

ក្នុងរយៈពេលតែ១ថ្ងៃ ស្ថានភាពតឹងតែងនៅកម្ពុជាបានក្លាយទៅជាធូរស្រាលស្ទើរមើលមិនយល់៖ ពីអ្នកនយោបាយបក្សប្រឆាំងជាប់គុក,ពីការចោទប្រកាន់ពីបាតុកម្មនៅសហរដ្ឋអាមេរិក, ពីការចង់បិទទីស្នាក់ការអង្គការសហប្រជាជាតិ...។ ទៅរកការលើកទោសលោក កឹម សុខា, ទៅរកភាពស្ងប់ស្ងាត់នយោបាយក្រៅប្រទេស,បំរុងលើកលែងទោសឱ្យអ្នកទោសនយោបាយទាំង២៧រូបផ្សេងទៀត...។ល។ គឺជាការបន្ធូរសម្ពាធនយោបាយកម្ពុជាយ៉ាងជាក់ស្តែងកិច្ចព្រមព្រៀងថ្មីត្រូវបានចុះហត្ថលេខា ដើម្បីសន្តិភាពនយោបាយទៅថ្ងៃមុខដោយលោក ហ៊ុន សែន ដែលគ្រប់អ្នកវិភាគសេរី តែងនិយាយថា "កិច្ចព្រមព្រៀងបានបង្កើតដោយដៃលោក ហ៊ុន សែន ហើយក៏នឹងរំលាយទៅវិញក៏ដោយដៃលោក ហ៊ុន សែន ដដែលយ៉ាងគ្មានអត់ឱន"។

គេពុំបានដឹងថា ការបន្ធូរបរិយាកាសនេះដោយសារអ្វីនោះទេ តែគេបានដឹងថា -លោក កឹម សុខា បានរួចពីការជាប់ទោសពន្ធនាគារ ហើយបានឡើងបុណ្យជា"ប្រធានគណបក្សភាគតិចនៅសភា" មានឋានៈស្មើនាយករដ្ឋមន្ត្រី -លោកមេឃុំបក្សប្រឆាំងដែលទើបនឹងកាត់ទោសជាប់គុក៥ឆ្នាំ ក៏បានត្រូវដោះលែង -អ្នកជាប់ទោសដោយសារពាក់ពន្ធនឹងការចោទប្រកាន់លោក សុខា នឹងត្រូវលើកលែងទោស នាឱកាសយ៉ាងខ្លីខាងមុខ..., តែគេបែរជានាំគ្នានិយាយថា "ធ្វើយ៉ាងនេះដើម្បីបំបែកគណបក្សសមរង្សីនឹងគណបក្សសិទ្ធមនុស្សឱ្យបែកបាក់គ្នារំលាយគណបក្សសង្គ្រោះជាតិចេញពីការបោះឆ្នោត"ទៅវិញ។

វិបត្តនយោបាយបានធ្វើឱ្យម៉ាស៊ីនរដ្ឋាភិបាលគាំងដំណើរៈ-ពីព្រោះច្បាប់នៃលទ្ធិប្រជាធិបតេយ្យបានត្រូវអនុវត្តន៏ខុសដោយមន្ត្រីគណបក្សប្រជាជនតែម្នាក់ឯង -ការគាំទ្រពីសហគមន៏អន្តរជាតិបានធ្លាក់ចុះ-ការគាំទ្រពីសំណាក់ពលរដ្ឋខ្លួនឯងក៏សង្ឃឹមមិនបាន -ចុងក្រោយបង្អស់ការគាំទ្រក្នុងគណបក្សខ្លួនឯងក៏មិនរឹងមាំ -ដូច្នេះគ្រោះថ្នាក់ "លិចទូកកណ្តាលទន្លេ"ក៏នឹងមកដល់..., លោក ហ៊ុន សែន បានសម្រេចចិត្តទៅរកការគាំទ្រពីប្រទេសចិនដែលជាសម្ព័ន្ធមិត្តខាងក្រៅមកជំនួស -ងាកទៅរកការវាយបំបែកគណបក្សប្រឆាំងខាងក្នុងប្រទេសដែលខ្លួនធ្លាប់មានបទពិសោធន៏ហើយធ្វើបានជោគជ័យតាំងពីឆ្នាំ១៩៩៤ នឹងបន្តបន្ទាប់ដោយសារមហិជ្ឈតាចង់រក្សារបបរាជានិយមរបស់ព្រះបរមរាជ


ហ៊ុន សែន


សម រង្ស៊ី


កឹម សុខា


កែម ឡី

វាំងធ្វើឱ្យលោក ហ៊ុន សែន អាចបង្វិលបានយ៉ាងងាយស្រួល។ តាំងពីឆ្នាំ២០១៣មកស្ថានភាពលំនឹងនយោបាយបានផ្លាស់ប្តូរៈ-គណបក្សហ៊្វុនស៊ិនប៉ិចដែលធ្លាប់ខ្លាំងជាងគេ ដោយសារដោតឫសរបស់ខ្លួនទៅនឹងព្រះបរមរាជវាំងបានចុះខ្សោយដោយព្រះមហាក្សត្រថ្មីមិនមានមហិច្ឆតាដូចព្រះបីតាដែលបានចូលទីវង្គត់បាត់ទៅហើយទេ-ព្រះមហាក្សត្រថ្មីមិនបានបង្ហាញមហិច្ឆិតាដូចព្រះបីតាព្រះអង្គក្រៅតែពីការដឹងគុណជំពោះមាតាបិតាតែប៉ុណ្ណោះនោះទេ-គណបក្សសង្គ្រោះជាតិបានកើតឡើងពីបក្សប្រឆាំងដែលពីមុនមាន២ឥឡូវប្រមូលបុំគ្នាជាកម្លាំងថ្មីតែមួយយ៉ាងរឹងមាំមានឫសគល់នៅជាមួយការស្មោះត្រង់ប្រជាជាតិ-សង្ឃឹមការគាំទ្រពីគណកម្មការបោះឆ្នោតជាតិគ.ជ.ប. ដូចពេលបោះឆ្នោតលើកមុនក៏បានកន្លងទៅហើយដែរ -សង្ឃឹមលើការគាំទ្របត្តូរផ្តាច់នៅក្នុងបក្សប្រជាជនក៏បានថយចុះដោយសារលោក ហ៊ុន សែន ធ្វើនយោបាយគ្រួសារនិយមជ្រុលទៅហើយ..., ទាំងនេះនឹងបុល់ការវិភាគសមរមថា "ទោះជាលោក សម រង្ស៊ី មិននៅក្នុងប្រទេសក៏កម្លាំងបក្សរបស់លោកនៅមានកម្លាំងរឹតតែធំសម្រាប់ការបោះឆ្នោតនាពេលខាងមុខតែដដែល, ការបែកបាក់គ្នារវាងលោកកឹម សុខា នឹង លោក សម រង្ស៊ី ដោយសារចង់ធ្វើធំនឹងបង្ហាញពីការ"ឆោតល្ងង់ដែលជាបទពិសោធន៏អតីតកាលមិនមានការចងចាំ"។

បុគ្គលិកលក្ខណៈរបស់លោក ហ៊ុន សែន គឺមាន"ជំនឿតែអំណាចបុគ្គលនឹងកម្លាំងទ័ព", បរិវាគាត់ទោះជាលោក ឈាង វុន លោក ផៃ ស៊ីផាន់, លោកអង្គ វង្សវត្តានា... ដែលធ្លាប់ស្គាល់ប្រទេសប្រជាធិបតេយ្យច្បាស់លាស់ ក៏ពុំបានផ្តល់ដំណោះស្រាយ"ឈ្នះ-ឈ្នះ"ដែលលោក ហ៊ុន សែន ចង់បាននោះឱ្យគាត់ទទួលយកបាននៅឡើយ..., ដែលទាំងនេះហើយដែលផ្តល់ការទស្សន៏ទាយថា"ប្រជាពលរដ្ឋនឹងទម្លាក់ពួកគាត់ចោល" នាពេលបោះឆ្នោតខាងមុខនោះ។

ខុសគ្នានឹងសម្ព័ន្ធភាពលោក សម រង្ស៊ី - កឹម សុខា ដែលបានទៅ "រៀនរំងាប់ចិត្តក្នុងព្រះពុទ្ធសាសនា" មុននឹងទៅធ្វើនយោបាយ -អ្នកទាំង២មានជំនឿទៅលើអំណាចនឹងកម្លាំងពលរដ្ឋ ,មិនដែលរួញរា ហើយបង្ហាញពីការតស៊ូការពារប្រជាជាតិប្រកបដោយលក្ខណៈជា "បុគ្គលក្លាហានមិនមានការនឿយហត់" -មានជំនឿលើទំនាក់ទំនងមនុស្សមិនដូចគ្នាមែនតែមានវិន័យស្របគ្នាក្នុងការក៏សាងជាតិ..., ដែលគេអាចគិតថា "បើ សម រង្ស៊ី មិនបាននៅបោះឆ្នោតដោយការរារាំងដ៏កំសាករបស់ ហ៊ុន សែន ក្តី ក៏អាចមកជួយជាតិជាៈ នាយករដ្ឋមន្ត្រី នាពេលឈ្នះឆ្នោតបានដែរ,ប្រជាជាតិខ្មែរត្រូវតែ"បង្ហាញការអរគុណអ្នកទាំង២ នឹងសហសេរិក" ដែលជួយជាកម្លាំងចិត្តនឹងកាងារ ចំពោះការលះបង់នឹងការរំដោះជាតិដ៏ខ្ពង់ខ្ពស់នេះឱ្យដូចគ្នានឹងវិរបុរស កែម ឡី ដែលប្រជាពលរដ្ឋធ្លាប់ផ្តល់កិត្តិយសលើភាពក្លាហានរបស់គាត់ចំពោះការបំភ្លឺជាតិខ្មែរដែរ។

ការខំប្រឹងបំបែកគណបក្សសង្គ្រោះជាតិមិនឈប់ឈរ ដោយលោក ហ៊ុន សែន ច្បាស់ជា "មិនមែនជាភាពក្លាហានទេ គឺជាភាពស្លន់ស្លោ" ចំពោះការបាត់បង់អំណាចបុគ្គល។ ខំប្រឹងធ្វើល្អជាមួយលោក កឹម សុខា ហើយទម្លាក់លោក សម រង្ស៊ី ចោល ជា "បំណងប្រាថ្នាអាក្រក់" នៅពីក្រោយខ្នង គឺ"ចង់បង្កើតឈឺចាប់បង្កើតការរំលាយគណបក្សជាសត្រូវខ្លួន."..។ ចុះបើគេមិនឈឺចាប់គេមិនបែកបាក់ទៅវិញ, សេចក្តីប្រាថ្នាឱ្យគេឈឺចាប់នឹងប្រាថ្នាឱ្យគេបែកបាក់នោះ"នៅតែជាការឈឺចាប់នឹងការបែកបាក់របស់ខ្លួនឯងដដែល"៕






# សុខផល ប៉ែន ទើបនឹងត្រឡប់ពីកម្ពុជាវិញ តែមិនបានឃើញភាពរីកចំរើននៃកម្ពុជាទេ

**ខ្មែរផុសស.រ.អា**

**ឡូវែល:** មកដល់ឡូវែលវិញភ្លាមបន្ទាប់ពីទស្សនកិច្ចនៅកម្ពុជានាខែវិច្ឆិការនឹងដើមខែធ្នូ លោក សុខផល ប៉ែន បានថ្លែងប្រាប់ខ្មែរផុសថា "ខ្ញុំខានទៅកម្ពុជា៨ឆ្នាំហើយ នៅពេលទៅដល់ភ្នំពេញខ្ញុំនឹកថា កម្ពុជានឹងបង្ហាញខ្ញុំថា នឹងមានភាពរីកចំរើនប្លែកពីមុន... ប៉ុន្តែគួរឱ្យស្តាយ, ខ្ញុំបែរជាបានឃើញប្រជាពលរដ្ឋខ្មែររស់នៅដោយគ្មានការគ្រប់គ្រងអ្វីទាំងអស់នរណាធ្វើអ្វីបានរស់នៅយ៉ាងម៉េចបានក៏រស់ទៅតាមចិត្តទៅ។ សុខផល ជាប្រធានយុវជនគណបក្សសង្គ្រោះជាតិនៅសហរដ្ឋអាមេរិក បានទៅដល់ភ្នំពេញនៅថ្ងៃទី៨ វិច្ឆិកា ជាមួយលោករ៉តនី អេលិយ៉ុត អតីតអភិបាលក្រុងឡូវែល,មានការខកចិត្តដោយបានឃើញចរាចរភ្នំពេញចង្អៀតគាំងដោយអនាធិបតេយ្យ (បានន័យថា មិនគោរពច្បាប់ចរាចរក៏មិនអីដែរ), បានឃើញរង្គសាលបំរើដោយយុវនារីវ័យក្មេងរាប់រយពាន់ រីកដុះដាលដូចផ្សិត (ដែលធ្វើការងារពង្វក់ស្មារតីនឹងគ្មានអនាគត់),បានឃើញមនុស្សរស់នៅដោយគ្មានការថែររក្សានឹងធានាសុខភាព(សូម្បីតែម្ហូបអាហារក៏មានជាតិពុលគ្រប់កន្លែង),បានឃើញទីក្រុងដែលគ្មានកន្លែងចតឡានដែលម្ចាស់ហាងចតឡានខ្លួនឯងអ្នកឯទៀតគ្មានកន្លែងចតសម្រាប់ចូលទិញឥវ៉ាន់ ឬមកធ្វើការ...។ល។ លោក រ៉តនី អេលីយ៉ុត ដែលទៅកម្ពុជាលើកនេះ ជាលើកទី២ គឺចង់ឃើញនឹងយល់ពីកម្ពុជាពិតប្រាកដជាប្រទេសដើមកំណើតរបស់ប្រជាពលរដ្ឋមួយចំនួនដែលបានមករស់នៅឡូវែលយ៉ាងកកកុញប្រមាណជា២-៣ជំនាន់ហើយ តែលោកនៅតែមិនទាន់យល់ពីពលរដ្ឋទាំងនោះច្បាស់លាស់នៅឡើយ នៅពេលមិនទាន់បានឃើញប្រភពនៃកន្លែងរស់នៅដើមរបស់គេ។

លោក សុខផល ប៉ែន នឹងលោក រ៉តនី អេលិយ៉ុត បាននាំជំនួយប្រមាណជិត៣ពាន់ដុល្លា ដែលជាអំណោយរបស់ប្រជាពលរដ្ឋឡូវែលនឹងនៅតំបន់ជុំវិញ ដើម្បីទៅចែកជូនក្រុមយុវជននឹងប្រជាពលរដ្ឋដែលនៅតាមបណ្តាខេត្តជាជនបត់មានខេត្តព្រះសីហនុ ខេត្តបាត់ដំបង បន្ទាយមានជ័យ: មានអំណោយជាអង្ករ ជាសៀវភៅ ប៊ិច ខ្មៅដៃ មាស៊ីនបញ្ចាំងរូបភាព សម្រាប់សិក្សា ៨គ្រឿង...។ អ្នកដំណើរពីអាមេរិកទាំង២រូប ក៏បានទៅមើលដល់កន្លែងដាក់ម៉ាស៊ីនបូមទឹក៥កន្លែង ដែលជាអំណោយបងប្អូនខ្មែរនៅរដ្ឋម៉ាសាឈូសិត គឺជួយឱ្យមានទឹកស្អាតប្រើប្រាស់សម្រាប់គ្រួសារ នឹងសម្រាប់អ្នកភូមិ។ លោក សុខផល និយាយថា:"យើងទាំងពីរជាអ្នកនាំពាក្យនៃការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅពីប្រជាពលរដ្ឋ ដែលបានទទួលអំណោយជូនដល់សប្បុរសជននៅក្រៅប្រទេស មានជាអាទិលោក ឌេវីដ សេន, ហាងអមរា ជនី បញ្ញា, ហាងកាត់សក់ ឡូវែល, ដេវិដ សៅ, ណុប ថា ជួយអង្ករ១តោន, លោកតូនី នៅរ៉ូស្ទ័រ ជារួមគឺអរគុណដល់ខ្មែរទាំងអស់នៅឡូវែលនេះ..."។

យើងបានចូលទៅទីស្នាក់ការកណ្តាលគណបក្សសង្គ្រោះជាតិទៅជួបលោក កឹម សុខា ដែលកំពុងត្រូវគាបសង្កត់ឱ្យនៅក្នុងទីស្នាក់ការច្រើនខែ, ទៅដល់ក្រុងព្រះសីហនុ, ទៅដល់បាត់ដំបង រហូតដល់ទល់ដែនថៃទៅដល់បាងកកទៅជួបគ្រួសារលោក កែម ឡី, ទៅដល់កន្លែងកើតហេតុសម្លាប់លោក កែម ឡី ផងដែរ... គ្រប់កន្លែងយើងតែងតែទទួលការគាំទ្រយ៉ាងកក់ក្តៅពីពលរដ្ឋខ្មែរយើង...។

មានហេតុការពិសេសមួយដែលខ្ញុំមិនដឹងថាជាការតាមដាន ឬជារឿងចៃដន្យ គឺនៅពេលយើងកំពុងជុបលៀងអាហារជាមួយទ្រង់ ស៊ីសុវត្ថិ ធម្មិកោ នៅក្រុងព្រះស៊ីហនុ, ស្រាប់តែឧត្តមសេនីយ ហ៊ុន ម៉ាណែត ចូលមកភោជនីយដ្ឋានជាក្រុមដូចយើងដែរ... គេដើរចាប់ដៃគេគ្រប់តុមកដល់តុយើង ក៏គេចចេញទៅវិញ ទំនងជាបានឃើញលោក រ៉តនីយ អេលិយ៉ុត នឹង ទ្រង់ ធម្មិកោ ទើបគេចចេញយ៉ាងនេះ។

លោកអតីតអភិបាលក្រុងនៅធ្វើទស្សនកិច្ច៨ថ្ងៃជាមួយគ្នាលោកត្រឡប់មកឡូវែលវិញមុន, ចំណែកឯ សុខផល ប៉ែន នៅបន្ត២អាទិត្យទៀត ដើម្បីជួបប្រស្រ័យទាក់ទងសមាជិកសមាជិកាយុវជនគណបក្សនឹងសម្រាកជួបជុំគ្រួសារ ទើបត្រឡប់មកឡូវែលវិញ៕


សុខផល ប៉ែន ពេលទៅដល់ភ្នំពេញ


ប្រធានចលនាយុវជននៅសៀមរាប ហៅអាចារ្យធំ




លោក រ៉ដនី អ៊ីយ៉ុត , កឹម សុខា , សុខផល ប៉ែន



## បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីពេទ្យ និងការគ្របដណ្តប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

### អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្តប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784

**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់ សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

# ការផលិតនឹងប្រើប្រាស់កញ្ឆាឥឡូវបានក្លាយជាស្របច្បាប់ម៉ាសាឈូសិត

# Marijuana legalized in Mssachusetts

**ដោយខ្មែរផុសស.រ.អា.**

ឡូវែលទើបនឹងបោះឆ្នោតអនុញ្ញាត្តិឱ្យប្រើកញ្ឆានៅរដ្ឋម៉ាសាឈូសិតបានច្បាប់នេះនឹងចូលជាធរមាននៅខែមករាឆ្នាំ២០១៧ខាងមុខនៅរដ្ឋម៉ាសាឈូសិតនេះហើយ។ គេតែងតែនិយាយពីគុណវិបត្តិនៃ"កញ្ឆា",ប៉ូលិសប្រដេញចាប់អ្នកជក់ អ្នកលក់ អ្នកទិញ នឹងអ្នកដឹកជញ្ជូនយ៉ាងគគ្រឹកគគ្រេងស្រាប់តែ"ប្រជាមតិ"បានបញ្ជាឱ្យកែប្រែទម្លាប់ចាស់នេះទៅវិញ តើបានន័យយ៉ាងណា?

**រួមសេចក្តីមកថា: កញ្ឆាស្របច្បាប់**

**១-**ប្រើជាលក្ខណ:កំសាន្តអនុញ្ញាត្តិឱ្យប្រើដល់មនុស្សអាយុពី២១ឆ្នាំឡើងទៅ

**២-**នៅផ្ទះអាចរក្សាបាន១០"អោន"ដាក់ក្នុងដប ឬកំប៉ុង

**៣-**ទៅក្រៅផ្ទះអាចយកតែ១"អោន"ទៅជាប់នឹងខ្លួនបាន

**៤-**អាចដាំនៅផ្ទះបាន៦ដើម បើផ្ទះនៅម្នាក់ឯង -បើផ្ទះមានគ្នាច្រើនអាចដាំបាន១២ដើម

**៥-**ធ្វើអំណោយទៅអ្នកដ៏ទៃធ្វើបានតែតិចជាង១"អោន"

**៦-លក់ដូរកញ្ឆា:** នៅតែខុសច្បាប់នៅឡើយលើកលែងតែមានអាជ្ញាប័ណ្ណឱ្យលក់រាយ ទើបលក់បាន **-ហេតុអ្វីក៏កញ្ឆាប្រែជាស្របច្បាប់?**

ជួប ជាមួយលោក"តូក"នៅឡូវែលដែលធ្លាប់ជាអ្នកផលិតនឹងជាអ្នកជក់កញ្ឆាច្រើនឆ្នាំបាននិយាយថា "អ្នកដែលមានឥទ្ធិពលប្រឆាំងនឹងការប្រើកញ្ឆាខ្លាំងជាងគេ គឺហាងលក់ភេសជ្ជ:


លោក តូក





គ្រឿងស្រវឹង ពីព្រោះតែអ្នកជក់កញ្ឆាមានកាន់តែច្រើនអ្នកផឹកគ្រឿងស្រវឹងក៏ចុះចំនួន"... តើកញ្ឆាមានលក្ខណ:សម្បត្តិ យ៉ាងណា?

ផ្ទុយពីសុរា,លោកតូកនិយាយថា "នៅពេលដែលស្រវឹងស្រាធ្វើឱ្យមនុស្សក្លាហានតែការប្រើកញ្ឆាធ្វើឱ្យមនុស្សខ្លាចច្បាប់ ខ្លាចបើកឡានប៉ះគេ ខ្លាចការវាយតប់គ្នា, នៅពេលស្រវឹងកញ្ឆា គឺបន្ថយភាពក្លាហាន..."។ នៅតុកាហ្វេនៅហាងគុយទាវភ្នំពេញ **តទៅទំព័រទី ១១**



# ACTIVE DAY® | SENIOR CARE®

## Under the same management as Lowell Elder Care

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ -www.seniorcarectrs.com and www.activeday.com

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យ មានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាស ដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺ គ្រប់គ្រាន់ បន្ទប់អានសៀវភៅបន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ពិធីបុណ្យខ្មែរ និងព្រឹត្តិការណ៍សាសនា
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Open 7 Days a Week

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Observe Khmer Holidays & Religious Events
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

## ព័ត៌មានខ្លីៗ...

**១-លោក អ៊ុន ឫទ្ធី ជាប្រធានគណបក្សសង្គ្រោះជាតិសាខា "អាមេរិកខាងជើង" :** យើងទើបនឹងទទួលដំណឹងថា លោក អ៊ុន ឫទ្ធី អតីតសមាជិកក្រុមប្រឹក្សាក្រុងឡូវែលបានជាប់ឆ្នោតទទួលការតែងតាំងជាប្រធានគណបក្សសង្គ្រោះជាតិសាខាសហរដ្ឋអាមេរិកជំនួសលោក រី គា នៅកាលីហ្វ័រញ៉ាដែលបានបញ្ចប់អាណត្តិ២ឆ្នាំរបស់លោក។ នៅពេលសួរថា "តើការឡើងជាប្រធានសាខាសហរដ្ឋអាមេរិកនឹងបញ្ចប់ការបែងចែកគណបក្សសង្គ្រោះជាតិ"អាមេរិកខាងជើង" នឹងសាខា "សហរដ្ឋអាមេរិក" ដែរឬទេ?" លោក អ៊ុន ឫទ្ធី តបថា "ឥតទេ! តែលោកចង់ធ្វើការបង្រួបបង្រួមគ្នារវាងសាខាទាំង២ឱ្យបានក្នុងអាណត្តិរបស់លោក"។


រិទ្ធី អ៊ុង

គួររំលឹកថាប្រធានសាខា"អាមេរិកខាងជើង"មាន ប្រធាន គឺ វេជ្ជបណ្ឌិត ចាន់ ទូច នៅឡូវែល ហើយសមាជិកនៃសាខានេះច្រើនជាសមាជិកដែលស្មោះត្រង់នឹងលោក សម រង្ស៊ី ៕

## ២- លោក សម រង្ស៊ី នៅអាមេរិក

លោក សម រង្ស៊ី កំពុងធ្វើដំណើរមកសហរដ្ឋអាមេរិក, នៅវ៉ាស៊ីនតុនឌីស៊ីលោកបានដាក់ពាក្យបណ្ដឹងទៅតុលាការអាមេរិកាំង ដើម្បីឱ្យក្រុមហ៊ុនប្រេងសាំងអាមេរិកាំង"សឺប្រុង"នៅកម្ពុជា"កាល់តិច" បញ្ចេញរូប "វិដេអូ"នៃការបាញ់សម្លាប់លោក កឹម ឡី បង្ហាញសាធារណជន។ កាសែតវីដេអូដែលដាក់ថតប្រចាំការនៅហាងកាល់តិចបានត្រូវបាត់ពីកន្លែងខ្លះថា ប៉ូលិសខ្មែរជាអ្នកប្រមូលយកជាឯកសារតែពុំមាន



សម រង្ស៊ី      កែម ឡី

នរណាបានដឹងពីវាសនានៃកាសែតវិដេអូនោះទៅដល់ណានៅឡើយទេ។ គេសង្ឃឹមថា ការដាក់ពាក្យប្ដឹងរបស់លោក សម រង្ស៊ី នឹងផ្ដល់ឱ្យមានការវិវត្តន៍ថ្មីលើវិបត្តន៏នយោបាយកម្ពុជាជាមិនខាន៕

## ៣-ប្រឡងយកសំបុត្របើកបររថយន្តជាភាសាខ្មែរ

massDOT Massachusetts Department of Transportation Registry of Motor Vehicles

ថ្ងៃ១៩ធ្នូ២០១៦- ក្រសួងដឹកជញ្ជូនរដ្ឋម៉ាសាឈូសិត MassDot DMV បានចេញព័ត៌មានជូនសាធារណជនថា "ក្រសួង "ម៉ាសដុត" បានចញ្ចូលច្បាប់"ប្រឡងបើកបររថយន្តថ្មី"ជា២៦ភាសាថែមទៀត"។ ម៉ាស៊ីនធ្វើ "តែស្ដស្វ័យប្រវត្តិ" សម្រាប់ប្រឡងយកប័ណ្ណបើកបរប្រភេទ ឌី (Class D)លើផ្លូវសាធារណនឹងប្រើប្រាស់ភាសាចំនួន២៦ ដែលនៅក្នុងនោះមានភាសាខ្មែរ-បារាំង-ឡាវ-វៀតណាម-ថៃ-ចិន-ជប៉ុន...។ ភាសាទាំងនោះ នឹងត្រូវអនុវត្តន៏ជាទូទៅនៅក្នុងរដ្ឋទាំងមូល ដើម្បីសម្រួលការប្រឡងដោយចុចសំនួរចម្លើយយកចំនួនពិន្ទុនឹងជៀសវាងការពិបាកយល់ភាសានឹងការបន្លំផង។

ក្រសួងក៏មានដាក់ឱ្យប្រើនូវភាសាសញ្ញាកាយវិការស្វ័យប្រវត្តិសម្រាប់អ្នកមកប្រឡងដែលស្ដាប់មិនឮថែមទៀតផង។

CONTACT

MassDOT Press Office: 857-368-8500



# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
### Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហ៊ែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# មូលនិធិសហគមន៏ឡូវែលសម្រាប់ផ្តល់អាហារូបករណ៏ជួយដល់និស្សិតមធ្យមសិក្សាជាមួយនឹងចំណាយនៅមហាវិទ្យាល័យឡូវែល

**ថ្ងៃទី៩ ខែធ្នូ ២០១៦**

ម៉ាស-គោលបំណងនៃមូលនិធិសហគមន៏ឡូវែល គឺបង្កើនគុណភាពរបស់ប្រជាជនដែលរស់នៅឡូវែលនឹងតំបន់"មីរីម៉ាកវ៉ាឡេ"។ មូលនិធិសហគមន៏កសាងសហគមន៏ដែលរឹងមាំដោយភ្ជាប់សប្បុរសជនទៅអង្គការមិនយកកម្រៃនឹងនិស្សិត។ កាលពីឆ្នាំមុនមូលនិធិសហគមន៏បានផ្តល់រង្វាន់$១,៧លាន ជាថវិការជំនួយនឹងជាអាហារូបករណ៏ទៅដល់អង្គការមិនយកកម្រៃនឹងនិស្សិតដោយសារសប្បុរសធមិនៃអ្នកធ្វើអំណោយ។

មូលនិធិសហគមនិគ្រប់គ្រងទាយជ្ជទានប័ត្ត $៤លានសម្រាប់ជាជំនួយដល់និស្សិតវិទ្យាល័យឡូវែលជាមួយនឹងចំណាយអប់រំនៅមហាវិទ្យាល័យដោយចែកអាហារូបករណ៏នៅរៀងរាល់ឆ្នាំតាមអំណោយកិត្តិយសនៅកម្មវិធិរាត្រីរបស់វិទ្យាល័យ។

នៅឆ្នាំ២០១៦ និស្សិត២៤០រូបនៅវិទ្យាល័យឡូវែលបានទទួលការផ្តល់អាហារូបករណ៏សរុប $៤២១,000 ។ អាហារូបករណ៏ផ្តល់ជាជំនួយដល់ចំណាយលើការបង់ថ្លៃសាលានៅចន្លោះពី $២៥0 ដល់ $៥,000។

លក្ខខណ្ឌនៃការផ្តល់ថវិការអាហារូបករណ៏អាចថាមានតែម្យ៉ាង ក៏ដូចជាមានច្រើនយ៉ាងដូចគ្នានឹងនិស្សិតនៅវិទ្យាល័យដែរ។ យើងមានអាហារូបករណ៏សម្រាប់និស្សិតអន្តោប្រវេសន៏ជំនាន់ទី១, ការសិក្សាផ្នែក"ថែរទាំសុខភាព នឹង "អ្នកថែជម្ងឺ", និស្សិតដែលរៀនពូកែរពិសេស, នឹងនិស្សិតដែលបានបង្ហាញពីការប្តូរផ្តាច់ជួយដល់សហគមន៏។

ជាឯកជន, ជាគ្រួសារ, នឹងជាក្រុមហ៊ុនសប្បុរសជន បានបង្កើតអាហារូបករណ៏ចំនួនជាង ២00 នៅទំនេរសម្រាប់ជួយមនុស្សចាស់ឱ្យប្រឡងជាប់នៅវិទ្យាល័យមានបំណងបន្តទៅរៀននៅមហាវិទ្យាល័យទៀត។ ម្ចាស់អំណោយអាចបង្កើតថវិកាអាហារូបករណ៏ ដែលឆ្លុះបញ្ចាំងបេក្ខជនដ៏ប្រើបំផុតរបស់ខ្លួនបាន។ អាហារូបករណ៏មានន័យណាស់ សម្រាប់ផ្តល់កិត្តិយសដល់អ្នកដែលខ្លួនស្រឡាញ់ ហើយអនុញ្ញាត្តឱ្យក្រុមគ្រួសារនឹងបុគ្គលបង្កើតកេរដំណែលបន្តបាន។

អាហារូបករគាំទ្រការសិក្សានៅមហាវិទ្យាល័យរបស់និស្សិតក្នុងតំបន់ដែលត្រូវការជំនួយបន្តិចបន្តួច។ ជាងពាក់កណ្តាលអ្នកទទួលរង្វាន់គឺជាមនុស្សដំបូងបង្អស់នៅក្នុងគ្រួសារ ដែលបានទទួលសញ្ញាប័ត្រមហាវិទ្យាល័យ។ ចិត្តសទ្ធារបស់សប្បុរសជនម្ចាស់អាហារូបករណ៏ គឺមានឥទ្ធិពលយ៉ាងអស្ចារ្យ លើនិស្សិតនឹងគ្រួសាររបស់គេ។

នៅឆ្នាំ២០១៧ វិទ្យាល័យឡូវែលជូនកិត្តិយសដល់"រាត្រីផ្តល់រង្វាន់"។ ការដាក់ពាក្យសុំនឹងផ្តើមនៅថ្ងៃទី៣១ខែមករា, និស្សិតថ្នាក់បញ្ចប់នៅវិទ្យាល័យឡូវែលអាចសុំតាមការបំពេញបែបបទតាម"អនឡាញ"។ ការឆប់ទទួលពាក្យ គឺនៅថ្ងៃ២៨ ខែកុម្ភៈ២០១៧។ នៅឆ្នាំមុន, ៨0% នៃនិស្សិតដែលបំពេញពាក្យសុំបានទទួលរង្វាន់ទាំងអស់។



គណកម្មការជ្រើសរើស គឺជាសមាជិកសហគមន៏, គ្រូបង្រៀន, មាតាបិតា, នឹងម្ចាស់អំណោយជាអ្នកវាយតម្លៃលើពាក្យសុំរបស់និស្សិត។ និស្សិតដែលត្រូវបានជ្រើសរើសឱ្យទទួលអាហារូបករណ៏នឹងត្រូវបានជូនដំណឹង ហើយនឹងត្រូវអញ្ជើញឱ្យមកចូលរួមជាកិត្តយសនៅរាត្រីចែករង្វាន់ដែលប្រព្រឹត្តទៅនៅខែឧសភា។

ប្រសិនបើលោកអ្នកជាសប្បុរសជនចង់ដឹងបន្ថែមពីថវិការអាហារូបករណ៏,ឬក៏ជានិស្សិតចង់ដាក់ពាក្យសុំអាហារូបករណ៏, សូទូរស័ព្ទទៅមុលនិធិសហគមន៏ លេខ ៩៧៨-៩៧0-១៦00 ឬក៏ចូលទៅមើលវេបសាយ www.glcfoundation.org

ចង់ដឹងអំពី"មូលនិធិសហគមន៏ឡូវែល"បង្កើតពិឆ្នាំ១៩៩៧, មូលនិធិសហគមន៏ឡូវែលបានកែរលំអរគុណភាពជីវិតនៅឡូវែលដោយកសាងធនធានពីការធ្វើអំណោយ,ភ្ជាប់ម្ចាស់អំណោយទៅនឹងអង្គការមិនយកកម្រៃនឹងធ្វើកម្មវិធិ,ធ្វើឱ្យថវិការទៅជាមានប្រយោជន៏,នឹងផ្តល់នូវការដឹកនាំដើម្បីបុព្វហេតុសហគមន៏។ មូលនិធិសហគមន៏លើកដំកើងស្មារតីធ្វើអំណោយទានរបស់ប្រជាពលរដ្ឋរបស់គ្រួសាររបស់ក្រុមហ៊ុននឹងរបស់ការងារមិនយកកម្រៃឱ្យទៅដល់សមត្ថភាពនៃការប្តូរពេលវេលា។ ឆ្នាំមុនតានរយៈអំណោយសប្បុរសជន,មូលនិធិសហគមន៏អាចឱ្យរង្វាន់ជាង$១.៧លានទៅសហគមន៏ឡូវែល៕

# Greater Lowell Community Foundation Scholarship EndowmentHelps Students at Lowell High School with the Cost of College

**December 9, 2016**

Lowell, MA-The goal of the Greater Lowell Community Foundation is to improve the quality of people's lives in Greater Lowell and the Merrimack Valley. The Community Foundation builds a stronger community by connecting donors to nonprofit organizations and students. Last year, the Community Foundation awarded $1.7 million in grants and scholarships to nonprofits and students through the generosity of donors.




The Community Foundation manages a $4 million endowment for Lowell High School which helps students with the cost of a collegeeducation by distributing scholarships each year through the Lowell High School Honor Awards Night Program.

In 2016, 240 students at Lowell High School were awarded scholarships totaling $421,000. Scholarship awards assist students with the cost of tuition and range between $250 to $5,000.

The criteria for scholarship funds are as unique and diverse as the students at Lowell High School. There are scholarships for first-generation immigrants, healthcare and nursing majors, students who excel in academics, and students who have shown a commitment to community service.

Individual, family, and corporate donors have created over 200 scholarships that are available to graduating seniors at Lowell High School who are pursuing a college education. Donors can create scholarship funds to reflect their ideal candidate. Scholarships are a meaningful way to honor a loved one and allow a family or individual to create a legacy.

Scholarships support the college education of local students who work hard but need a little extra help. Over half of the recipients are the first in their families to obtain a college degree. The generosity of scholarship donors has a tremendous impact on students and their families.

The 2017 Lowell High School Honor Awards Night Application opens on January 31st. Seniors at Lowell Highs School can apply by completing an online application. The deadline to apply is February 28, 2017. Last year, 80% of students that completed an application received a scholarship award.

A selection committee made up of community members, teachers, parents, and donors evaluate student applications. Students selected to receive a scholarship are notified of their award and invited to attend Honor Awards Night in May.

If you are a donor and want to learn more about creating a scholarship fund, or you are a student and want to apply for a scholarship fund, call the Community Foundation at 978-970-1600 or visit our website at www.glcfoundation.org.

The article is submitted by George Nugent, Deputy Director of the Greater Lowell Community Foundation.

ABOUT THE GREATER LOWELL COMMUNITY FOUNDATION

Founded in 1997, the Greater Lowell Community Foundation improves the quality of life in Greater Lowell by building philanthropic resources, connecting donors to nonprofit organizations and programs, making effective grants, and providing leadership to address community issues. The Community Foundation leverages the philanthropic spirit of citizens, families, corporations and nonprofits to best meet the challenges of changing times. Last year, through the generosity of our donors, the Community Foundation to award more than $1.7 million to the Greater Lowell community.

## តមកទំព័រទី ០៦ ការផលិត និងប្រើប្រាស់កញ្ឆា...

នាព្រឹកដ៏សែនត្រជាក់ក្រោមសូន្យភ្ញៀវខ្មែរ ២-៣នាក់ទៀត និយាយពីគុណសម្បត្តិនៃការប្រើកញ្ឆាថា "តាមពិតការស្រវឹងកញ្ឆាមកតែពីអ្នកប្រើដាក់កញ្ឆាខ្លាំងហួសកម្រឹត ទើបបានជាស្រវឹងតែបើដាក់តែបន្តិចទៅវិញ វានឹងជួយសុខភាពទៅវិញទេ! ពីព្រោះប្រជាមតិគេអនុញ្ញាត្តិឱ្យប្រើកញ្ឆានេះ ក៏ព្រោះតែកញ្ឆាមានគុណសម្បត្តិខាងព្យាបាលមនុស្សបានច្រើន"... តើកញ្ឆាអាចព្យាបាលជម្ងឺអ្វីខ្លះទៅ?

លោកតូកនិយាយថា"ខ្ញុំមានឧទាហរណផ្ទាល់ខ្លួនមួយ គឺនៅពេលខ្ញុំជក់កញ្ឆាម្តង១ខ្ញុំតែងតែខ្លាចមិនហ៊ានកាន់ចង្កូតបើកឡានទេ...មិនមែនហ៊ានដូចជាគេផឹកស្រាទេ តែស្រវឹងហើយបើកឡានលឿនតែមិនដឹងថាលឿននៅឡើយទេ ហ្នឹងហើយដែលនាំឱ្យមានគ្រោះថ្នាក់នោះ" លោកបន្តថា "ភ្នែកខ្ញុំវិញ ពីដើមមើលអ្វីមិនឃើញទេ តែនៅពេលខ្ញុំយកជ័រកញ្ឆាមកញីលើចិញ្ចើមច្រើនដង, ពេលបែកញើសហៀរចូលភ្នែក១នោះឡើងក្តៅហើយព្យាបាលរបៀបនេះ បានជាហើយបានមើលឃើញច្បាស់មកវិញរហូតដល់សព្វថ្ងៃនេះ..."។ បន្ថែមថា "...នៅមានការព្យាបាលជម្ងឺផ្លូវចិត្តជាច្រើនករណីទៀតដែលអ្នកជម្ងឺបានធូរស្បើយដោយគ្រាន់តែប្រើកញ្ឆាជាថ្នាំបានលទ្ធផលយ៉ាងសាកសិទ្ធិ"... ចុះបើគេចង់ប្រើជាថ្នាំ តើទៅរក



អ្នកឯទៀតដែលនៅជុំវិញតុកាហ្វេនិយាយបន្តថា "មានបងប្អូនខ្មែរយើងជាច្រើនគេជក់កញ្ឆាសម្រាប់បន្ថយជម្ងឺលើសឈាមកំចាត់ជម្ងឺចាស់១ឈឺសន្លាក់ដៃជើង ឈឺនញ្ជឹងក ខ្លះទៀតព្យាបាលជម្ងឺសើរស្បែក... ដែលមកទល់ថ្ងៃនេះគេព្យាបាលយ៉ាងមានប្រសិទ្ធិភាពណាស់តែនៅជាការលួចលាក់ពីព្រោះតែច្បាប់ប្រើកញ្ឆាមិនទាន់បើកសម្រាប់សាធារណជននៅឡើយ..." អ្នកនិយាយនោះ កញ្ឆាបាននៅឯណា?

លោកតូកឆ្លើយថា"ដោយសារច្បាប់មិនអនុញ្ញាត្តិ គេទិញកញ្ឆាបានដោយលួចលាក់ពីផ្សារងងឹត,តែគេក៏អាចទិញជាថ្នាំបាននៅឱសថដ្ឋានហ្វាម៉ាស៊ីបានដែរ តែត្រូវមានវេជ្ជបញ្ជា ឬមានអាជ្ញាប័ណ្ណទើបទិញបាន គេលក់ជាអោន (ស្មើ២,៥ក្រាម)!" ៕

(នៅមានតទៅលេខក្រោយ)

State of Rhode Island
Department of Administration
PROGRAMMING SERVICES OFFICER

The State of Rhode Island has the following opportunity available within the Office of Diversity Equity and Opportunity (ODEO)

**PROGRAMMING SERVICES OFFICER**
**ODEO/MINORITY BUSINESS ENTERPRISE COMPLIANCE OFFICE**
**Disadvantaged Business Enterprise Program**
**Salary Range: $61,604 - $69,759 Annually**
**Application Period: December 11, 2016 – January 14, 2017**

***Description/Requirements:***
To assist the ODEO/Minority Business Enterprise Compliance Office (MBECO) with complex duties involving the development, management, and/or operations within that office; to perform responsible administrative work relevant to the certification of **Disadvantaged Business Enterprises**, a program which is under the direction of the MBECO, and to perform other related duties. A thorough knowledge of federal regulations pertaining to the disadvantaged business enterprise program preferred.

***EDUCATION AND EXPERIENCE:***

- **Education:** Such as may have been gained through: graduation from a college of recognized standing with specialization in business management, social sciences or a related field; and
- **Experience:** Such as may have been gained through: employment in a supervisory position in a private or public agency involved in the development, management, reorganization, and/or operation of a service program.
- Or, any combination of education and experience that shall be substantially equivalent to the above education and experience.

***To Apply:***
***Please visit the APPLY RI Website at: WWW.APPLY.RI.GOV***

*THE STATE OF RHODE ISLAND IS AN EQUAL OPPORTUNITY EMPLOYER*

Collegiate Charter School
of Lowell



ធម្មនុញ្ញសាលា Collegiate ឡូវែល (CCSL) គឺជាការសិក្សាដោយឥតគិតថ្លៃ សាលាធម្មនុញ្ញត្រៀមសាកលវិទ្យាល័យសាធារណៈដោយផ្តល់នូវកម្មវិធីប្រកួតប្រជែងការអប់រំនៅក្នុងបរិស្ថានដែលមានសុវត្ថិភាពនិងមានរចនាសម្ព័ន្ធ។

- កម្មវិធីសិក្សាយ៉ាងម៉ត់ចត់ដោយការប្រើប្រព័ន្ធអប់រំ SABIS
- ការផ្តោតទៅលើ គណិតវិទ្យា និង ភាសាអង់គ្លេស
- ច្បាប់ក្នុងការប្រតិបត្តិនិងឯកសណ្ឋាន
- មុននិងក្រោយកម្មវិធីសាលារៀន
- កម្មវិធីសិក្សាភាសាអង់គ្លេសត្រូវបានផ្តល់ជូននូវគ្រប់កម្រិតថ្នាក់ទាំងអស់
- កម្មវិធីសិក្សាមត្តេយ្យពេញថ្ងៃ
- សិល្បៈ តន្ត្រី កីឡា កុំព្យូទ័រ
- កម្មវិធីខ្សែអក្សរតន្ត្រី (ក្រោយពេលម៉ោងសិក្សា)
- មានផ្តល់ជូននូវយានជំនិះ

"ខ្ញុំដឹងថាខ្ញុំនឹង ត្រៀមខ្លួនពេល ខ្ញុំបានចូលរៀននៅសាកលវិទ្យាល័យលំដាប់កំពូល ដែលជាគោលដៅចុងក្រោយរបស់ខ្ញុំ"
សិស្សថ្នាក់ទី 5

**ចុះឈ្មោះថ្ងៃនេះ!**
**ថ្នាក់មត្តេយ្យទៅដល់ថ្នាក់ទី7**
**ផុតកំណត់: ថ្ងៃទី 28 ខែកុម្ភៈឆ្នាំ 2017**

សំរាប់ពត៌មានបន្ថែមអំពី CCSL និងចុះឈ្មោះ
សូមទាក់ទងមកការិយាល័យចុះឈ្មោះ:
1857 Middlesex Street
Lowell, MA 01851
ទូរស័ព្ទ: (978) 458-1399
គេហទំព័រ: lowell.sabis.net
អ៊ីម៉ែល: lowell@sabis.net

*Education for a changing world.*
Member of the SABIS Network

ឌី ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី

# ក្រុមអ្នកវិភាគចំអកចំពោះការគំរាមរបស់លោក សម រង្ស៊ី ដែលថានឹងកម្ទេចអ្នកដែលមិនទទួលស្គាល់លទ្ធផលឆ្នោត

**ដោយ ខូលីន ម៉ីយន៍ | ថ្ងៃច័ន្ទ ទី ១៩ ខែធ្នូ ឆ្នាំ២០១៦**

ខណៈគណបក្សរបស់ខ្លួនកំពុងស្ថិតក្នុងដំណើរការចរចាដើម្បីឱ្យមានការដោះលែងមន្ត្រីសិទ្ធិមនុស្សកំពុងជាប់ពន្ធនាគារលោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងបានសន្យាកាលពីចុងសប្តាហ៍ថា នឹង "កម្ទាត់" អ្នកនៅក្នុងគណបក្សប្រជាជនកម្ពុជាទាំងឡាយណាដែលមិនគោរពជ័យជម្នះដែលអាចកើតមាននៅក្នុងការបោះឆ្នោតឆ្នាំ២០១៨។

ដោយសង្ខេបការឆ្លើយតបរបស់ខ្លួនចំពោះសំណួរអំឡុងកិច្ចសម្ភាសន៍តាមវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) ថា តើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សកាន់អំណាចរបស់លោកនឹងទទួលយកការចាញ់ឆ្នោតដែរឬក៏អត់នោះ លោក សម រង្ស៊ី បានសរសេរនៅលើទំព័រហ្វេសប៊ុកថា ពួកគេគ្មានជម្រើសទេ។

លោកបានសរសេរថា "នៅក្នុងឆ្នាំ២០១៨ គណបក្សសង្គ្រោះជាតិនឹងបង្កើតរដ្ឋាភិបាលស្របច្បាប់ថ្មីមួយ ហើយអ្វីដែលនៅសល់ពីគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន នឹងគ្រាន់តែជាក្រុមឧទ្ទាមដែលនឹងត្រូវកម្ទេចដោយរដ្ឋាភិបាលស្របច្បាប់ តាមរយៈការបញ្ជាកងកម្លាំងប្រដាប់អាវុធជាតិដែលមានការគាំទ្រពីសហគមន៍អន្តរជាតិដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ ស្តីពីប្រទេសកម្ពុជា"។

លោក សម រង្ស៊ី បានលើកឡើងទៀតថា ប្រទេសវៀតណាមដែលលើកបន្តុបមេដឹកនាំគណបក្សប្រជាជនកម្ពុជាឱ្យឡើងកាន់អំណាចជិត៤ទសវត្សរ៍កន្លងមកនេះក៏នឹងគាំទ្ររដ្ឋាភិបាលថ្មីដឹកនាំដោយគណបក្សសង្គ្រោះជាតិដែរ ហើយច្រានចោលការគំរាមប្រើអំពើហិង្សារបស់លោក ហ៊ុន សែន ក្រោយគណបក្សសង្គ្រោះជាតិទទួលជ័យជម្នះក្នុងការបោះឆ្នោត។

លោកបានមានប្រសាសន៍ថា "ប៉ុន្តែការលើកឡើងពីបញ្ហានៃការផ្ទេរអំណាចក្នុងឆ្នាំ២០១៨ ក្នុងពេលឥឡូវនេះគឺគ្រាន់តែជាផ្នែកនៃសង្គ្រាម-នយោបាយ និងសង្គ្រាមចិត្តសាស្ត្រប៉ុណ្ណោះ ដោយសារលោក ហ៊ុន សែន តែងតែកម្លា ពេលលោកគំរាមបក្សសង្គ្រោះជាតិថានឹងកើតមានសង្គ្រាមស៊ីវិល? ប្រសិនបើលោកចាញ់ឆ្នោតនាពេលខាងមុខ"។

លោក ហ៊ុន សែន បានបង្កើនការព្រមានរបស់លោកអំពីសង្គ្រាមស៊ីវិលមុនការបោះឆ្នោតជាតិឆ្នាំ ២០១៣ ហើយបានបន្តលើកឡើងថា ជ័យជម្នះរបស់គណបក្សសង្គ្រោះជាតិនឹងនាំទៅរកអំពើហិង្សាដោយចៀសមិនផុតឡើយ ដោយលោកបានព្រមាននៅចុងឆ្នាំ២០១៥ថា ការប៉ុនប៉ងណាមួយនៅក្នុងការផ្តួលរំលំមេបញ្ជាការយោធា និងអគ្គស្នងការនគរបាលជាតិបច្ចុប្បន្ននឹងឈានទៅរកប្រតិកម្មប្រឆាំងតបវិញ។



ការព្យាកររបស់លោក សម រង្ស៊ី ដែលបច្ចុប្បន្នត្រូវបានរារាំងមិនឱ្យចូលមកក្នុងប្រទេសកម្ពុជាវិញ ផ្ទុយទាំងស្រុងពីអ្វីដែលត្រូវបានលើកឡើងដោយប្រវត្តិវិទូ និងអ្នកវិភាគដែលជឿថា លោក ហ៊ុន សែន ទំនងជានៅតែគ្រប់គ្រងយោធាភាគច្រើនដដែល ទោះបីជាបន្ទាប់ពីចាញ់ឆ្នោតក៏ដោយ ហើយប្រើប្រាស់អង្គភាពដ៏ស្មោះស្ម័គ្រដើម្បីឱ្យខ្លួននៅតែបន្តកាន់អំណាចប្រសិនបើចាំបាច់។

លោក ដេវិដ ឆាណ្ឌល័រ (David Chandler) ដែលជាប្រវត្តិវិទូមួយរូបបានលើកឡើងអំឡុងកិច្ចសម្ភាសន៍មួយតាមវិទ្យុកាលពីពីខែឧសភាថា កម្ពុជានឹងមិនមានលទ្ធិប្រជាធិបតេយ្យដែលដំណើរការនោះឡើយ លុះត្រាតែលោក ហ៊ុន សែន ស្លាប់ ឬត្រូវបានផ្តួលរំលំដែលលោកលើកឡើងថា អាចកើតឡើងបានមានតែតាមរយៈកងកម្លាំងទេ។

លោកបានមានប្រសាសន៍អំឡុងពេលនោះថា "ខ្ញុំមិនដែលនិយាយតាមកម្មវិធីរបស់អ្នកឬកន្លែងណាផ្សេងថា លោក ហ៊ុន សែន គួរតែត្រូវបានផ្តួលរំលំដោយកងកម្លាំងឡើយ ប៉ុន្តែទោះជាយ៉ាងណា លោកនឹងមិនត្រូវបានផ្តួលរំលំនោះទេ"។ **តទៅទំព័រទី២៣**

# Rainsy Threatens to 'Crush' Election Holdouts; Analysts Scoff

BY COLIN MEYN | DECEMBER 19, 2016

As his party is in the midst of negotiations to free jailed human rights workers, opposition leader Sam Rainsy over the weekend promised to "crush" those in the CPP who do not respect a prospective 2018 national election victory.

—News Analysis—

Summarizing his response to the question of whether Prime Minister Hun Sen and his ruling party would accept an election loss, put to him during a Voice of America interview, Mr. Rainsy wrote on Facebook that they would have no choice.

"In 2018, the CNRP will form a new and legitimate government and what will remain from Hun Sen's CPP will just be a bunch of rebels who will be crushed by the legitimate government commanding the national armed forces with the support of the international community on the basis of the 1991 Paris Peace Agreements on Cambodia," he wrote.

Mr. Rainsy said that Vietnam, which installed CPP leaders currently in power almost four decades ago, would also support a new CNRP government, and dismissed Mr. Hun Sen's threats of a violence following a CNRP election victory as bluster.

"But raising now this issue of transfer of power in 2018 is just part of a political and psychological war, with Hun Sen bluffing—as always—when he threatens the CNRP with a civil war if he loses the forthcoming elections," he said.

Mr. Hun Sen ramped up his warnings of civil war ahead of the 2013 national election, and has continued to say that a CNRP victory will inevitably lead to violence, warning late last year that any effort to remove the current military commander and National Police chief would lead to a backlash.

The predictions by Mr. Rainsy, who is currently banned from returning to Cambodia, fly in the face of that made by historians and analysts, who are convinced that Mr. Hun Sen would likely maintain control of much of the military even after an election loss, and use loyal units to remain in power if necessary.

Historian David Chandler said in a radio interview in May that Cambodia would not have a functioning democracy until Mr. Hun Sen was dead or overthrown, which he said would only happen through force.

"I'm never going to say on your program or anywhere else that Hun Sen should be overthrown by force, but he is not going to be overthrown any other way," he said at the time.

Fellow historian Milton Osborne offered a similar analysis in an article for The Interpreter last month, but noted that a CNRP victory was by no means guaranteed, and that a fragile power-sharing agreement might be an inevitable result if such an outcome eventuated.

"In short, on past and present evidence…Hun Sen and his party are ready to take all actions that they see as necessary to stay in office.

**Continued to Page 23**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# នៅពីក្រោយកំណែទម្រង់ប្រជានិយម គណបក្សប្រជាជនប្តេជ្ញាយកឈ្នះ

**ដោយ បែន សុខហ៊ាន | ថ្ងៃច័ន្ទ ទី ១៩ ខែធ្នូ ឆ្នាំ២០១៦**

នៅសន្និបាតលើកទី៤០របស់គណបក្សកាលពីចុងសប្តាហ៍គណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចបានព្យាករថានឹងទទួលបានជ័យជម្នះទៀតនៅក្នុងការបោះឆ្នោតឃុំសង្កាត់នៅឆ្នាំក្រោយ និងការបោះឆ្នោតជាតិនៅឆ្នាំបន្ទាប់ដោយទទួលបានការគាំទ្រគោលនយោបាយប្រជានិយមកាលពីពេលថ្មីៗនេះរួមមានការបញ្ចុះថ្លៃប្រើប្រាស់អគ្គិសនី និងការផ្តល់ដីធ្លីបន្ថែមទៀតដល់ប្រជាពលរដ្ឋក្រីក្រ។

យោងតាមប្រតិចារឹកនៃសុន្ទរកថា របស់លោកបានឱ្យដឹងថា លោក ហេង សំរិន ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជាបានថ្លែងទៅកាន់អង្គសន្និបាតកាលពីថ្ងៃសៅរ៍ថា "គណបក្សក៏បានត្រៀមលក្ខណៈ និងធ្វើគ្រប់កិច្ចការទាំងឡាយទៅតាមច្បាប់ និងបទបញ្ជានីតិវិធីបោះឆ្នោតដើម្បីឈានឆ្ពោះទៅដណ្តើមប្រៀបឈ្នះសម្រាប់ការបោះឆ្នោតផងដែរ"។

ម្ចាស់ផ្សារទំនើបបាយ័នបងស្រីហ៊ាំងបានឱ្យដឹងថា អតិថិជនរបស់ផ្សារទំនើបភាគច្រើនជាជនជាតិបរទេស ព្រោះពួកគេមិនចូលចិត្តក្លិនឆ្អេះឆ្អាប និងបរិយាកាសអាប់អួរគ្មានអនាម័យនៅតាមបណ្តាទីផ្សារនានាឡើយ ទោះបីជាតម្លៃរបស់ផលិតផលនៅតាមផ្សារទំនើបថ្លៃជាងនៅតាមបណ្តាទីផ្សារនានាក្តី ក៏ជាការនិយមរបស់ជនជាតិបរទេស ។

បងស្រីបានបញ្ជាក់ថា បន្លែ ផ្លែឈើត្រីសាច់ដែលបានជ្រើសរើសដាក់លក់នៅក្នុងផ្សារទំនើបនេះមានប្រភពដូចបណ្តាទីផ្សារនានាអញ្ចឹងដែរ មានលក់ជាបន្លែធម្មតា និងបន្លែសរីរាង្គ និងមានម៉ូយខ្លះបានយកមកបោះឱ្យផ្ទាល់តែម្តង ។

មូលហេតុតម្លៃថ្លៃជាងនៅតាមបណ្តាទីផ្សារនានាដោយសារផលិតផលដែលបានដាក់លក់មានការសិរិតសំរាំង និងបន្ទុកចំណាយផ្សេងៗខ្ពស់។ ទិដ្ឋភាពរបស់ផ្សារទំនើបបាយ័ន មានទ្រង់ទ្រាយធំគួរសម ប៉ុន្តែបងស្រីបានបញ្ជាក់ថា គ្រួសាររបស់បងស្រីក៏ទៅទិញម្ហូបអាហារនៅតាមបណ្តាទីផ្សារនានាដូចប្រជាជនទូទៅដែរ ។



នៅខាងក្នុងទីផ្សារទំនើបមានម៉ាស៊ីនត្រជាក់សំរាប់ថែរក្សាគុណភាពទំនិញបរិស្ថានធំទូលាយ និងអនាម័យល្អប្រកបដោយផាសុខភាពបន្លែត្រីសាច់មានវេចខ្ចប់និងបិទស្លាកថ្ងៃខែ សុពលភាពអាហារព្រមទាំងតម្លៃនៅលើកញ្ចប់និមួយងាយស្រួលអតិថិជនជ្រើសរើសទៅតាមតំរូវការដោយមិនចាំបាច់សួរនាំនិងតថ្លៃជាមួយអ្នកលក់ ហើយបើអាហារលក់សល់នៅតាមផ្សារទំនើបខ្លះដូចជាផ្សារទំនើបឡាក់គីក៏មានបិទស្លាកបញ្ចុះតម្លៃនៅលើនោះតែម្តង និងមានអ្នកលក់ក្មេងៗជាច្រើនអ្នករង់ចាំផ្តល់សេវា។

រីឯទិដ្ឋភាពនៅក្នុងផ្សារសាមគ្គីវិញមានមនុស្សដើរទិញម្ហូបប្រជ្រៀតគ្នាដីហុយទ្រលោមបងស្រីអឿនដែលជាស្ត្រីមេផ្ទះបាននិយាយថា ផ្សារស្រុកយើងខ្វះអនាម័យណាស់មនុស្សមកផ្សារដើរប្រជ្រៀតគ្នាព្រមជាមួយនឹងកង់ម៉ូតូដែលបើកកាត់ផ្សារធ្វើឱ្យបរិយាកាសក្នុងផ្សារសាមគ្គីនេះមានផ្សែងនិងធូលីកខ្វក់ហើយពេលមេឃភ្លៀងមានភក់ល្បាប់ដើរប្រឡាក់ជើង និងគំនរសំរាមមានក្លិនស្អុយដែលបង្ករឱ្យកើតជំងឺផ្តាសាយឆ្លងគ្នាទៅវិញទៅមកប៉ុន្តែខ្ញុំមិនរួញរាឡើយ ខ្ញុំតែងតែមកទិញម្ហូបនៅផ្សារនេះជាប្រចាំព្រោះតែនៅជិតគេហដ្ឋាន រីឯតម្លៃថោកជាងនៅតាមទីផ្សារទំនើប។

នៅតាមទីផ្សារទូទៅបន្លែផ្លែឈើខ្លះបានបេះស្រស់ពីចំការមកលក់នៅក្នុងផ្សារផ្ទាល់តែម្តង ដូចជាត្រសក់ ស្ពៃ ផ្លែស្វាយ ចេក ល្ហុត ជាដើម ។ល។ រីឯត្រីស្រស់ៗទើបនេសាទបានពីបឹងទន្លេសាប ត្រូវបានអាជីវករដាក់លក់ផ្ទាល់ក្នុងផ្សារតែម្តង។

តាមការឱ្យដឹងពីអ៊ំស្រី អ៊ឹង ហ៊ុចណៃ អតីតអាជីវករបាននិយាយថា ពីមុនគាត់ធ្លាប់លក់ត្រសក់ជ្រក់ ដោយត្រាំត្រសក់ជ្រក់ ហើយជាមួយម្សៅពណ៌សមួយកញ្ចប់ដើម្បីឱ្យឡើងពណ៌ស្រស់គួរឱ្យចង់ទទួលទានអ៊ំបានបញ្ជាក់ថា ម្សៅពណ៌សនោះគឺមានផលប៉ះពាល់មិនល្អដល់សុខភាពអ្នកបរិភោគ ប៉ុន្តែនេះជាមុខរបរបើមិនដាក់ឱ្យមានពណ៌ស្រស់ ស្អាតអ្នកលក់បារម្ភណ៍ថា គ្មានអ្នកមកទិញលក់អត់ដាច់។ អ៊ំបានបន្តថា អ្វីៗក៏គេប្រើប្រាស់ថ្នាំគីមីដែរហើយម្សៅពណ៌សនេះគេបានបញ្ចូលទៅក្នុងត្រីងៀត ប្រហុក និងគ្រឿងផ្អាប់ដ៏ទៃទៀត ដែលមានពណ៌ខ្មៅលក្ខណៈធម្មជាតិក៏ប្រែជាពណ៌ស **តទៅទំព័រទី ២៦**

តមកពីទំព័រទី ១២

## ក្រុមអ្នកវិភាគចំអកចំពោះការគំរាម...

ប្រវត្តិវិទូបន្ទាប់ដែលមានឈ្មោះ មីលថុន អូសស្បន (Milton Osborne) បានផ្តល់ការវិភាគស្រដៀងគ្នានេះនៅក្នុងអត្ថបទមួយរបស់ The Interpreter កាលពីខែមុន ប៉ុន្តែបានគូសបញ្ជាក់ថា ជ័យជម្នះរបស់គណបក្សសង្គ្រោះជាតិមិនទទួលបានការធានាទាល់តែសោះ ហើយថាការព្រមព្រៀងចែករំលែកអំណាចដ៏ផុយស្រួយចៀសមិនផុតនោះឡើយ ប្រសិនបើលទ្ធផលបែបនេះកើតមានមែននោះ។

លោកបានសរសេរថា "និយាយជារួមមកបើផ្អែកលើភ័ស្តុតាងកាលពីមុន និងពេលបច្ចុប្បន្ននេះ...លោក ហ៊ុន សែន និងគណបក្សរបស់លោកត្រៀមខ្លួនរួចហើយ ក្នុងការចាត់គ្រប់វិធានការដែលពួកគេមើលឃើញថា ចាំបាច់នៅក្នុងការបន្តកាន់អំណាចតទៅមុខទៀត។ មិនថាវិធានការរបស់ពួកគេស្រមតាមទស្សនទាននីតិរដ្ឋរបស់បស្ចិមប្រទេស ឬក៏អត់នោះឡើយ គឺគ្មានការពិចារណាទេ"។

លោក មាស នី អ្នកវិភាគនយោបាយ និងជាអ្នកសិក្សាស្រាវជ្រាវបានលើកឡើងកាលពីម្សិលមិញថា វាលឿនពេកហើយសម្រាប់លោក សម រង្ស៊ី ក្នុងការធ្វើការប្រកាសបែបនេះ។

លោកបានមានប្រសាសន៍ថា "គណបក្សកាន់អំណាចនៅតែចង់បំបែកបំបាក់គណបក្សប្រឆាំងមួយនេះ។ គណបក្សសង្គ្រោះជាតិមិនគួរមានមោទនភាពជ្រុលក្នុងការនិយាយថាពួកគេនឹងឈ្នះឆ្នោតឡើយ"។ លោកបានបន្ថែមថា ការបង្កបញ្ហាបែបនេះមិនអាចជួយអ្វីបានទេសម្រាប់ដំណើរការក្រោយការបោះឆ្នោត ប្រសិនបើគណបក្សប្រជាជនកម្ពុជាពិតជាចាញ់មែននោះ។

លោកបានមានប្រសាសន៍ថា "ប្រសិនបើខ្ញុំជាលោក សម រង្ស៊ី ខ្ញុំនឹងមានការប្រុងប្រយ័ត្នចំពោះថា តើត្រូវចេញសេចក្តីថ្លែងការណ៍យ៉ាងម៉េច ទើបធ្វើឱ្យមានការផ្ទេរអំណាចមានដំណើរដោយរលូនប្រកបដោយសន្តិវិធី។ អ្វីៗដែលប៉ះពាល់ដល់យោធាគឺរសើបណាស់"។

លោក មាស នី បានយល់ស្របថា វៀតណាមមានជម្រើសតិចតួច ក្រៅពីទទួលយកការផ្លាស់ប្តូរ ប៉ុន្តែនឹងគិតគូរខ្ពស់ចំពោះការប្រព្រឹត្តមកលើពលរដ្ឋរបស់ខ្លួនដោយសារមានការព្រួយបារម្ភថា តើពួកគេនឹងត្រូវបានប្រព្រឹត្តមកលើយ៉ាងដូចម្តេច ដោយគណបក្សសង្គ្រោះជាតិដែលមេដឹកនាំរបស់ខ្លួនតែងតែប្រើពាក្យរើសអើងជាយូរមកហើយមកលើជនជាតិវៀតណាម។

លោកបានមានប្រសាសន៍ថា "ខ្ញុំគិតថា បន្ទាប់ពីពលរដ្ឋភាគច្រើនបោះឆ្នោតឱ្យគណបក្សសង្គ្រោះជាតិ វៀតណាមមិនអាចធ្វើ អ្វី បានទេ ប៉ុន្តែ យកចិត្តទុកដាក់ចំពោះការរស់នៅរបស់ជនជាតិវៀតណាមនៅកម្ពុជា"។

លោក ខាល ថាយ័រ អ្នកជំនាញប្រចាំតំបន់អាស៊ីអាគ្នេយ៍នៅបណ្ឌិតសភាកងទ័ពការពារអូស្ត្រាលី (Australian Defense Force Academy) បានលើកឡើងថា លោកមិនយល់ស្របទាល់តែសោះចំពោះការព្យាកររបស់លោក សម រង្ស៊ី ។

លោកបានលើកឡើងតាមអ៊ីម៉ែលថា "ខ្ញុំគិតថាសេណារីយ៉ូរបស់លោក សម រង្ស៊ី មិនអាចទៅរួចទេ។ ប្រសិនបើលោក សម រង្ស៊ី ត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់មកវិញហើយអំឡុងយុទ្ធនាការឃោសនាលោកទំនងជាកៀងគរបានការគាំទ្រនោះ ខ្ញុំព្យាករថា អ្វីៗអាក្រក់នឹងកើតមានឡើង។ លោក ហ៊ុន សែន និងរបបរបស់លោកនឹងមិនព្រមលះបង់អំណាចនោះឡើយ ហើយពួក គេនឹងរៀបចំការបោះឆ្នោត ដើម្បីធានាការវិលត្រឡប់មកកាន់អំណាចបន្តទៀត"។

លោកបានមានប្រសាសន៍បន្ថែមថា "ប្រសិនបើក្នុងហេតុផលណាមួយដែលការបោះឆ្នោតដែលត្រូវបានរៀបចំមិនអាចទៅរួច លោក ហ៊ុន សែន នឹងរកលេសអន្តរាគមន៍ ហើយសម្លាប់គណបក្សប្រឆាំង"។ លោកបានបន្ថែមទៀតថា ទាំងប្រទេសវៀតណាម និងប្រទេសចិននឹងមិនថ្កោលទោសការបង្ក្រាបដ៏ហិង្សាលើគណបក្សសង្គ្រោះជាតិឡើយប៉ុន្តែ ពួកគេនឹងចៀសវាងការគាំទ្រដោយបើកចំហ។

លោកបានថ្លែងថា "ទាំងប្រទេសចិន និងប្រទេសវៀតណាមសុទ្ធតែដឹងយ៉ាងច្បាស់ថា ប្រសិនបើពួកគេធ្វើអន្តរាគមន៍ដោយបើកចំហក្នុងការគាំទ្រលោក ហ៊ុន សែន ប្រឆាំងលោក សម រង្ស៊ី នេះអាចនឹងបញ្ឆេះឱ្យមានចលនាស្នេហាជាតិនិយមក្នុងចំណោមពលរដ្ឋខ្មែរប្រឆាំងពួកគេ"៕ **ស៊ុយឈាង**

Continued from page 12

## Rainsy Threatens to 'Crush'...

Whether their actions accord with western concepts of the rule of law is not a consideration," Mr. Osborne wrote.

Meas Ny, a political analyst and social researcher, said on Sunday that it was simply too soon for Mr. Rainsy to be making such pronouncements.

"The ruling party are still looking to break the opposition. The CNRP should not be too proud to think they will win the election," he said, adding that such provocations would do nothing to help the post-election process if the CPP did lose.

"If I were Sam Rainsy, I would be careful of how to release the political statement of how to be a more smooth and peaceful transition," he said. "Anything that affects the military could be very sensitive."

Mr. Ny agreed that Vietnam would have little choice but to accept change, though it would prioritize treatment of its own citizens out of concern for how they might be treated by the CNRP, whose leaders have a history of xenophobic rhetoric toward the Vietnamese.

"I think after a majority of people vote for the CNRP, Vietnam cannot do anything but take care of Vietnamese living in Cambodia," he said.

Carl Thayer, a Southeast Asia expert at the Australian Defense Force Academy, said that he fundamentally disagreed with Mr. Rainsy's projections.

"I do not think Sam Rainsy's scenario is remotely possible," he said in an email. "If Sam Rainsy is permitted to return and during the campaign it appears he is picking up support I predict things will prove nasty. Hun Sen and his regime are not going to give up power and they will manipulate the elections to ensure their return to power."

"If for any reason a manipulated election is not possible Hun Sen will find a pretext to intervene and dispatch the opposition," Mr. Thayer said, adding that neither Vietnam nor China would condemn a violent repression of the CNRP, though they would avoid overt support.

"Both China and Vietnam realise only too well that if they overtly intervened in support of Hun Sen against Sam Rainsy this could ignite Cambodian nationalism against them," he said.

តមកពីទំព័រទី ១៨

## ប្រជាជនហ្វីលីពីនតវ៉ាប្រឆាំងសង្គ្រាម...

គ្រឿងញៀនរបស់រដ្ឋាភិបាល។

អ្នកតវ៉ាហ្វីលីពីនក្នុងក្រុងភ្នំពេញបាននិយាយថា ក្រុមរបស់លោកប្រឆាំងច្បាប់ចំនួនពីរដែលកំពុងត្រូវពិចារណាដោយសភាហ្វីលីពីនដែលនឹងបន្ទាបអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌពីអាយុ១២មកត្រឹម៩ឆ្នាំ និងការដាក់ឱ្យប្រើទោសប្រហារជីវិតឡើងវិញ ចំពោះបទល្មើសមួយចំនួនក្នុងនោះមានទាំងបទល្មើសគ្រឿងញៀនផង។

ស្ថានទូតហ្វីលីពីនប្រចាំក្រុងភ្នំពេញមិនបានឆ្លើយតបទៅនឹងសំណើសុំការអត្ថាធិប្បាយទេ។

កាលពីខែតុលា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា រដ្ឋាភិបាលរបស់លោកមិនមានផែនការប្រើទោសប្រហារជីវិតឡើងវិញ ជាមធ្យោបាយកាត់បន្ថយការប្រើ និងលក់គ្រឿងញៀនខុសច្បាប់នៅកម្ពុជាទេ។

លោក ហ៊ុន សែន បានមានប្រសាសន៍ក្នុងសុន្ទរកថាទៅកាន់និស្សិតបញ្ចប់ការសិក្សានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចថា "កម្ពុជាមិនអាចប្រើប្រាស់ទោសប្រហារជីវិតលើជនឧក្រិដ្ឋបានទេ គឺត្រឹមតែដាក់ទោសមួយជីវិត គឺគ្រប់គ្រាន់ហើយ"។

នៅពេលនោះលោកនាយករដ្ឋមន្ត្រីបានអំពាវនាវឱ្យអាជ្ញាធរ និងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ "ធ្វើសកម្មភាពព្រមៗគ្នាដើម្បីឈានទៅបង្ក្រាបគ្រឿងញៀនដែលកំពុងរីករាលដាលពីប្រទេសមួយទៅកាន់ប្រទេសមួយ"។

លោក ជុំ សន្ទរី អ្នកនាំពាក្យក្រសួងការបរទេសបានបដិសេធមិនធ្វើអត្ថាធិប្បាយអំពីយុទ្ធនាការបង្ក្រាបគ្រឿងញៀនរបស់ប្រទេសហ្វីលីពីន ដោយលើកឡើងនូវនយោបាយមិនជ្រៀតជ្រែករបស់ប្រទេសកម្ពុជា។

លោកបានបង្វែរសំណួរអំពីការព្រមព្រៀងស្តីពី "សហប្រតិបត្តិការក្នុងការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន" ដែលគេរំពឹងថានឹងត្រូវចុះហត្ថលេខា ដោយលោក ហ៊ុន សែន និងលោក ឌូធឺតេ នៅសប្តាហ៍នេះ ទៅក្រសួងមហាផ្ទៃដែលអ្នកនាំពាក្យមិនអាចទាក់ទងបានទេ៕

**និត (រាយការណ៍បន្ថែមដោយ គុជ ណារ៉េន)**

រឿងប្រលោមលោក

# រឿងចៅពិន

**អារម្ភកថា**

**"ចៅពិន"** ជារឿងរ៉ាវរបស់ក្មេងតូចម្នាក់ទំនងជាអាយុ៥ឆ្នាំនាឆ្នាំ១៩៥០ គឺជារឿងក្នុងអត្ថបទសិក្សាដែលគ្រប់ក្មេងទើបនឹងចូលសាលាថ្នាក់កុមារដ្ឋាននាម៉្តុំពេលនោះ បានស្គាល់នឹងបានរៀនគ្រប់ៗគ្នា ពីព្រោះសៀវភៅថ្នាក់កុមារដ្ឋាននេះ បានត្រូវប្រើច្រើនឆ្នាំ នាជំនាន់ឆ្នាំ១៩៥០ ពុំមានផ្លាស់ប្តូរទេ។ ហេតុនេះហើយបានជា "ខ្មែរផុសស.រ.អា." ចាប់យករឿង"ចៅពិន"មកសរសេរជារឿងជីវិតកុមារ នាជំនាន់ឆ្នាំ ដែលខ្មែរកំពុងចេញពីអនានិគមបារាំង តើមានស្ថានភាពជីវិតយ៉ាងណា? វប្បធម៌ខ្មែរនាពេលនោះមានរូបរាងដូចម្តេច? ខ្ញុំពុំទាន់ឃើញមានអ្នកនិពន្ធណាសរសេរកំណត់រឿងនេះនៅឡើយទេ។ ដូច្នេះយើងសូមនាំអារម្មណ៍លោកអ្នកត្រឡប់ទៅរស់នៅជាមួយអតីតកាលរបស់"ចៅពិន"ដែលថ្វីត្បិតតែជារឿងសិប្បនិមិត្តតែបានដកស្រង់ពីជីវិតពិតនៃសង្គមខ្មែរជំនាន់មួយដែលគេកំពុងតែភ្លេចបន្តិចម្តងៗទៅហើយនោះដូចតទៅ:

**ខ្មែរផុសស.រ.អា.**

## ចៅពិនៈ ភាគ១

### ១១-ផ្សារកំពង់ស្ពឺ

ផ្សារនៃទីប្រជុំជនខេត្តកំពង់ស្ពឺ,ចៅពិនដូចក្មេងដទៃឯទៀត គ្មានតុក្កតាឬល្បែងអ្វីលេងច្រើនទេ ម្ល៉ោះហើយនៅពេលរើសបានខ្នងកង់កញ្ចាស់មួយដែលគេបោះចោលនាព្រៃសង្កែត្រង់ផ្លូវចុះទៅភូមិ"អូរឬស្សី" យកមកលេងធ្វើជាល្បែងប្រចាំថ្ងៃបាន, គឺគេយកខ្នងកង់ដែលគ្មានកាំនោះហើយ រួមនឹងបំណែកមែកឈើមួយមកវាយកង់នោះឱ្យវិលទៅមុខ ហើយខ្លួនប្រដេញតាមវាយពីក្រោយរត់ពេញជាយក្រុង ដូចជាគ្មានអ្វីធ្វើឱ្យរីករាយជាងនេះទៀតទេ, ស្លៀកខោខ្លីមួយចង្កេះកៅស៊ូ ឥតអាវ គ្មានស្បែកជើង ជាម្ចាស់នៃល្បែងលេងដ៏សំខាន់មួយ ហើយអាចរត់ផងលេងតាមមាត់ស្ទឹង"ព្រែកត្នោត"ក្បែរផ្សារផង ធ្វើឱ្យក្មេងៗឯទៀតដែលនៅជុំវិញផ្សារ ដណ្តើមលេងគួរឱ្យច្រណែនមិនតិចទេ។

ព្រឹកនេះចៅពិនរត់បែកញើសពេញខ្លួននៅពេលឃើញក្មេងៗឆ្លងស្ពានដែកត្រឡប់ចេញពីរៀនថ្ងៃត្រង់ ទើបរត់មកផ្ទះបងស្រីខ្លួន ដែលនៅក្បែរផ្សារដែរនោះវិញ។ ឃើញបែកញើសគ្នាយ៉ាងនេះ បងនីស្រែកដេញចៅពិន "ឱ្យទៅងូតទឹករួចមកញ៉ាំបាយ" ហើយឧទ្ទានថា:

-អូនពិនឯងធំប៉ុណ្ណឹងហើយមិនជួយធ្វើការអីបងសោះ គិតតែពីរត់លេង!

-អ្នកបងចង់ឱ្យខ្ញុំធ្វើអី ប្រាប់ខ្ញុំមក

-អីញ៉ាំបាយឱ្យហើយទៅ ចាំបងប្រាប់!

ថាហើយក៏ផ្តើមញ៉ាំបាយយ៉ាងរីករាយអង្គុយបត់ជើងនៅក្តារងឿផំមួយជាមួយនឹងក្មួយស្រីតូចៗ២នាក់ទៀត, បងប្រុសជាបងថ្លៃមិនទាន់មកពីធ្វើការនៅឡើយទេ គាត់តែងតែពិសារបាយ



តែម្នាក់ឯងពេលគាត់មកដល់នៅតុបាយម្ខាងទៀត នៅពេលបន្តិចទៀតនោះ។ បាយរួចហើយបងសូនីគាត់ថា:

-អូនពិនឯងបន្តិចទៀតមកនៅជាមួយបងហើយត្រូវចេះជួយកាងារបងផងណាខ្លួនឯងក៏ធំហើយដែរ! អូនឯងទៅលាហាលខោអាវក្មួយ



លើស្នូរងណោះ បងបានបោកវារួចហើយ!

-ម៉ាក់បានប្រាប់ខ្ញុំរួចហើយ ហើយថាបន្តិចទៀតខ្ញុំនឹងចូលរៀនផង មែនទេអ្នកបង?

-មែនហើយ ឯងនឹងគ្រប់អាយុចូលរៀនហើយណា! មើលវាស់ត្រចៀកទៅមើល? ចៅពិនក៏យកដៃឆ្វេងខ្លួន បោះរំលងក្បាលទៅស្ទាបត្រចៀកស្តាំវាល់ដងមិនដែលប៉ះត្រចៀកនោះសោះ តែពេលនេះក៏ស្រែកថា"ខ្ញុំវាស់ត្រចៀកដល់ហើយ! ខ្ញុំចូលរៀនបានហើយៗ!"។

ថាផង រត់ផង លោតកញ្ឆេងផង ទៅហាលខោអាវដែលបងស្រីឱ្យធ្វើ។

ចៅពិនសប្បាយចិត្តណាស់ នៅពេលមកលេងផ្ទះបងស្រីខ្លួនម្តងៗ ឥឡូវគេអាយុ៦ឆ្នាំហើយ, ឪពុកធ្វើជានាយទាហ៊ានបារាំងតែងតែផ្លាស់ទីតាំងពីកន្លែងមួយទៅកន្លែងមួយទៀតជារឿយៗកូនចៅក៏ត្រូវតែរកកន្លែងឱ្យវាជ្រកហ្នឹងហ្ន ដើម្បីឱ្យរៀនបាន។ បងស្រីសូនីបានត្រូវរៀបចំឱ្យមានប្តីតាំងតែពីអាយុ១៦ឆ្នាំមកម្លេះ ឥឡូវបានកូនស្រីពីរនាក់ហើយ ឈ្មោះ អាធា(អាយុ៣ឆ្នាំ) នឹងអាព្រឿង(ទើបដើរតិតាក់) តែនៅតូចៗណាស់នៅឡើយ។ បងថ្លៃចៅពិនធ្វើការនៅក្រសួងសុរិយោដីកំពុងស្ពឺ តែងតែជិះកង់ "ឌីរ៉ា" ពណ៌ប្រាក់របស់គាត់ទៅធ្វើការរាល់ថ្ងៃ, ហើយនៅរៀងរាល់ថ្ងៃឈប់សម្រាកគាត់តែងតែយកកង់គាត់មកខាត់សំអាតឱ្យឡើងភ្លឺរលោង។ បងវ៉ាន់ថនចូលចិត្តស្លៀកពាក់មានពណ៌អាវដាក់ក្នុងខោជានិច្ចពាក់ស្បែកជើង"គ្លុប" មិនចូលចិត្តពាក់ស្បែកជើង "ផ្ទាត់" ចេញក្រៅទេ, គាត់មានគ្រួសារជាអ្នករាចការនៅផ្ទះឈើខ្ពស់ពីដីមួយជាសម្បុកគ្រួសារបង្កើតរបស់គាត់នៅ"រកាធំ"ជាឃុំមួយនៅខាងជើងមិនឆ្ងាយពីប្រជុំជនខេត្តកំពុងស្ពឺទេ, ចៅពិនក៏ចូលចិត្តទៅលេងទីនោះណាស់ដែរ ពីព្រោះសម្បូរដើមស្វាយ ដើមពុទ្រា ដើមចេក ដែលខ្លួនអាចបេះបរិភោគបាន។ ក្រុមគ្រួសារបងវ៉ាន់ថនដែលនៅឯជើងនោះគឺជាបងៗស្រី២នាក់របស់គាត់

រីឯបងប្រុសជាប្តីបងស្រីម្នាក់នោះ គាត់ជាមេឃុំម្នាក់ ធ្វើការនៅឃុំ "ស្គុះ" ជាតំបន់ផ្នែកខាងត្បូងក្រុងកំពុងស្ពឺ។ បងមេឃុំតែងតែជិះម៉ូតូម៉ាក "ពុជ" ពណ៌ឈាមជ្រូករបស់គាត់ទៅធ្វើការជារាល់ថ្ងៃ តែដើម្បីទៅសាលាឃុំរបស់គាត់ដែរ, ម៉ូតូនោះលាន់ឮសម្លេងម៉ាស៊ីនខ្លាំងបន្តិចមែនតែមិនងាយខូចទេ។ បងមេឃុំស្គុះតែងតែទៅធ្វើការនៅឯត្បូងម៉ោង៦កន្លះជានិច្ចគាត់ត្រូវជិះម៉ូតូធ្វើដំណើរតាមផ្លូវជាតិកាត់តាមុខផ្ទះបងវ៉ាន់ថន ដែលជាផ្លូវតែមួយគត់ដែលចាក់កៅស៊ូខ្មៅរលើប នាទីក្រុងកំពង់ស្ពឺ, ជិះកាត់តាមស្ពានថ្ម រួចទៅចូលកាត់ផ្សារមុននឹងឆ្លងស្ទឹងព្រែកថ្នោតតាមស្ពានដែកមួយទៀតដែលនៅលើផ្លូវស្ពាននោះ គេក្រាលបន្ទះក្តារក្រាស់ៗឱ្យឡានតូចធំក៏អាចឆ្លងបានដែរ។ ផ្នែកខាងត្បូងនៃស្ពានដែកលែងជាតំបន់សេដ្ឋកិច្ចខេត្តទៀតហើយ គឺជាដំបន់រដ្ឋបាលដែលមានទីស្នាក់ការនគរបាលខេត្ត គ្រប់គ្រងដោយលោក"កុម្មីស៊ែ"ខ្មែរម្នាក់ដ៏មានអំណាចនៅជាប់របងគ្នានោះគឺបន្ទាយទាហ៊ាន"ជើងក្រហម"ជាទីបញ្ជាការដោយសក្តិពាបារាំងដែលទល់មុខគ្នានោះ មានបរិវេណដ៏ធំទូលាយជាជម្រកនៃរដ្ឋធនាគារក្រុង-សាលាខេត្តកំពង់ស្ពឺ នឹងវិមានលោកចៅហ្វាយខេត្ត ប៊ុនចាន់ប្លង់ដែលគេអាចឃើញម្តងម្កាលនាពិធីបុណ្យជាតិក្នុងក្រុងម្តងៗ គាត់មានមាឌធំសាច់សដូចបារាំងតែមុខមាត់ជាកូនចៅចិនតែទទួលកាគោរពយ៉ាងខ្លាំងពីពលរដ្ឋ និងពីបារាំងផងដែរ។ បងមេឃុំត្រូវជិះម៉ូតូត្រង់កាត់តំបន់អស់ទាំងនោះហើយតែត្រូវឆ្លងបន្ទាយទាហ៊ានបារាំងមួយទៀត គេតែងហៅថា បន្ទាយ"សក្តិ២តូម៉ា", ពីត្រឹមនេះទៅ គ្មានផ្លូវចាច់កៅស៊ូទៀតទេ គឺផ្លូវដីឆ្លងវាលស្រែបន្តិចទៀត ទើបដល់សាលាឃុំ"ស្គុះ"នោះ, ជាទីកន្លែង



ដែលគាត់ត្រូវផ្តើមធ្វើការរាល់ថ្ងៃនៅម៉ោង៧ព្រឹកដូចគ្នានឹងកន្លែងធ្វើការបង វ៉ាន់ថន ដែរ។

ញ៉ាំបាយថ្ងៃត្រង់រួចហើយ ចៅពិន ជួយបងស្រីជញ្ជូនចានទៅលាងរួចសម្អាតលន្លែងបាយរបស់ខ្លួននឹងមូរកន្ទេលយកទៅទុកការនេះចៅពិនធ្វើមិនខ្ជិលច្រអូសទេ ហើយក៏សប្បាយចិត្តនឹងជួយសម្រាលកាងារបងស្រីជាទីស្រឡាញ់របស់ខ្លួនផង។

**តទៅលេខក្រោយ**

# *For your special day...*







## សណ្ឋាគារយូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ

ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់ អាចនឹងជប់លៀងដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធីប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឱ្យរំភើបសម្រាប់មានឱកាសថតរូប នឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន, រាប់ទាំងបន្ទប់តូចសម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាច នឹងពិធីផ្ទាប់ពាក្យ...។

គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូន ស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

UMASS LOWELL Inn & Conference Center

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422
**www.uml.edu/icc**

តមកពីទំព័រទី ២២

# ប្រជាជនខ្មែរនិយមទិញទំនិញ...

និងគ្មានរុយរោម គ្មានដង្កូវទោះបីទុកចោលរយៈពេលយូរក៏ដោយ ចំណែកឯសណ្តែកបណ្តុះគល់ស្លឹកគ្រៃ ឬខ្ទឹមដែលហាន់ហើយ តែងប្រែពណ៌ស្រគាំដោយសារជាតិជ័រ ប៉ុន្តែអ្នកលក់បានដាក់ម្សៅពណ៌ស ធ្វើឱ្យបន្លែចិតហើយទាំងនោះ ឡើងពណ៌សស្គុះខុសពីលក្ខណៈដើម ចំណែកផ្លែដូងចិតហើយក៏ដូចគ្នាដែរគឺមានពណ៌សរតែម្តងបន្ទាប់ពីត្រាំម្សៅពណ៌សរួចមក។

បងប្អូននៅស្រុកស្អាងបាននិយាយថាអ្នកចំការតែងប្រើប្រាស់ថ្នាំគីមីទៅលើបន្លែផ្លែឈើដើម្បីទទួលបានផលភ្លាមៗតាមតំរូវការលក់លើទីផ្សារដូចជាផ្លែស្វាយជាដើម ។ល ។ ផ្លែស្វាយដែលគេដាំសំរាប់លក់គេតែងបាញ់ថ្នាំពន្លឿនអ័រមូនម្យ៉ាងធ្វើឱ្យមានផ្លែគ្រប់រដូវដែលខុសពីលក្ខណៈធម្មជាតិរបស់ស្វាយចំណែកឯផ្លែឈើដ៏ទៃទៀតក៏ដូចនេះដែរ ។

ការចែកចាយព័ត៌មាននៅតាមបណ្តាញសង្គមក៏ឃើញមានការចាក់បញ្ចូលថ្នាំគីមីទៅក្នុងសាច់មាន់ បង្គារ ក្តាម មឹក ដែលជាប្រភេទអាហារសមុទ្រក្លាហ្វេ ដើម្បីរក្សាអាហារទាំងនោះទុកឱ្យបានយូរនិងស្រស់ៗ ផ្លែឈើមួយចំនួនដូចជា ឡឹកខ្ចី ចាក់សារធាតុឱ្យឡើងពណ៌ក្រហមទុំស្រស់តែម្តង ។

ដូចនេះហើយទាមទារឱ្យស្ត្រីមេផ្ទះឆ្លាតវៃក្នុងការជ្រើសរើសទិញបន្លែត្រីសាច់ផ្លែឈើស្រស់ៗដែលគ្មានជាតិគីមីទាក់ទងនឹងសុវត្ថភាពចំណីអាហារនេះ អាជីវករ និងសន្តិសុខផ្សារបានប្រាប់ថា កាលពីមុនធ្លាប់បានឃើញអជ្ញាធរចុះមកត្រួតពិនិត្យយូរៗម្តង ប៉ុន្តែក្រោយៗមកមិនដែលបានឃើញអជ្ញាធរណាម្នាក់ ចុះមកត្រួតពិនិត្យចំណីអាហារមានផ្ទុកសារធាតុគីមី ឬខូចគុណភាពនោះទេ ។

ព្រលឹមស្រាងៗលើចិញ្ចើមថ្នល់អ្នកលក់ប្រញាប់ប្រញាល់រៀបចំបន្លែគ្រប់មុខដាក់ក្នុងកញ្ច្រែងតំរៀបគ្នានៅលើកន្ទេល

ក្រាលផ្ទាល់ដី មានដូចជា ត្រប់ ចេកអំបូង ត្រសក់ ស្វាយ ស្ពៃក្តោប សណ្តែកបណ្តុះ ម្រះក្រអៅឈូក បណ្តូលចេក ត្រកួន ស្ពៃក្រញ៉ាញ់ ផ្សិត សណ្តែក ត្រួចសើច ពពាយ អំពិលខ្ចី ផ្កាខាត់ណា ពងទា ត្រីឆ្អើ ដែលជាផលិតផលក្នុងស្រុក ហើយប្រជាជនទូទៅនិយមបរិភោគ បានមកចោមរោមសួរបន្លែនេះតម្លៃមួយគីឡូប៉ុន្មាន? ចំណែកឯអ្នកលក់វិញដៃថ្លឹងបណ្តើរមាត់ជាប់រវល់ឆ្លើយឆ្លងជាមួយអ្នកទិញបណ្តើរ ពូ ហេង មានអាយុជាង៤០ឆ្នាំបាននិយាយថា គាត់លក់បន្លែនៅផ្សារសាមគ្គីនេះជាង១០ឆ្នាំមកហើយ គាត់មិនមានគំរោងផ្លាស់ប្តូរមុខរបរផ្សេងទេដោយសារគាត់មិនពូកែខាងធ្វើស្រែចំការ ពូអាចទទួលបានប្រាក់ចំណេញពី ១០ម៉ឺន ទៅ១៥ម៉ឺនរៀលក្នុងមួយព្រឹកដោយសារការលក់បន្លែជាប្រចាំមិនដែលខានមួយថ្ងៃណាឡើយ ។ ពូលក់តែពេលព្រឹកទេ ចំណែកពេលល្ងាចពូឆ្លៀតទៅទិញបន្លែនៅស្រុកកំណើតឯភូមិព្រែកពោធិខេត្តកំពង់ចាមដើម្បីទុកលក់ពេលព្រឹកនៅផ្សារសាមគ្គីភ្នំពេញ ចំណែកឯភរិយានៅមើលថែរក្សាកូនៗ និងសត្វចិញ្ចឹមនៅផ្ទះឯស្រុកកំណើត ។ ចំណែកថ្លៃដើមគឺចំណាយតិចតួចអស់ត្រឹមមួយម៉ឺនប្រាំពាន់រៀលទៅពីរម៉ឺនរៀលសំរាប់ថ្លៃជួលកន្លែង ចំណែកឯអ្នកលក់ផ្សេងទៀតក៏មានស្ថានភាពស្រដៀងគ្នានឹងពូហេងអញ្ចឹងដែរ ទោះស្ថិតក្រោមកំដៅថ្ងៃ ឬភ្លៀងរលឹម ព្រមទាំងបរិយាកាសអាប់អួរ ធូលីហុយដែលជាប្រភពនៃមេរោគឆ្លងជំងឺផ្សេងៗដូចជាគ្រុនផ្តាសាយជាដើម ក៏ការលក់ដូរនៅតែប្រព្រឹត្តទៅជាធម្មតា ។

ប្រជាជនមានការបារម្ភណ៍ពីផលប៉ះពាល់នៃកសិផលបន្លែផ្លែឈើ ព្រមទាំងត្រីសាច់ដែលមានប្រភពពីបរទេសនិងក្នុងស្រុកមួយចំនួនដែលបានចែកចាយនៅលើទីផ្សារទំនើបនិងបណ្តាទីផ្សារក្នុងស្រុកនានាដែលមានផ្ទុកសារធាតុគីមីថ្នាំពុលកសិកម្មផ្សេងៗបង្កគ្រោះថ្នាក់ដល់សុខភាពរបស់ប្រជាពលរដ្ឋនិងសេដ្ឋកិច្ចគ្រួសារ ។ ដោយមើលឃើញនូវសក្តានុពលនេះទីផ្សារផលិតផលបន្លែសរីរាង្គត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ដូចជាអង្គការសេដាក់ ( CEDAC)


## រកអ្នកធ្វើការ

ខ្មែរផុសស.រ.អា រកបុគ្គលិកចេះ
និយាយនឹងសរសេរភាសាខ្មែរច្បាស់លាស់
យល់ភាសាអង់គ្លេស
សម្រាប់ការងារជាអ្នកសរសេរព័ត៌មាន។
សូមទូរស័ព្ទមកសូបិន **978-656 8141**



## ហាងធ្វើក្រចកដ៏សម្បូរភ្ញៀវនឹង សាឡុងជួលថ្លៃ $៨00/ខែ ដូចគ្នានឹងមានហាងខ្លួនឯង

-ដុសខាតសំអាតក្រចក៣ នឹង តុ"ប៉េឌីគួរ"៣
-ថ្លៃទឹក-ភ្លើង រាប់បញ្ចូលហើយ

អស័យដ្ឋាន 933 Gorham St. Lowell, MA 01852
សូមទូរស័ព្ទរក ដាយ៉ាណា Diana 978-641 1455




## ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

**ព្រះអភិធម្មទើបខ្លឹម ធម៌ក្រៅពីនោះគ្រាន់តែជាល្បោយ**

ខាងលើនេះ ជាពាក្យរបស់ប្រធានគណបក្សជួងបានពោល តើនេះជាពាក្យពិតឬទេ? ក្នុងអដ្ឋង្គិកមគ្គ ប្រែថា មគ្គប្រកបដោយអង្គ៨ ឬហៅថា មជ្ឈិមា បដិបទា ប្រែថា ការប្រតិបត្តិមាគ៌ាកណ្តាល បើរួមឲ្យខ្លី បានដល់សីល សមាធិ បញ្ញា ។ បើចាត់ចូលក្នុងបិដកបី សីលចាត់ចូលក្នុងវិន័យបិដក សមាធិចាត់ចូលក្នុងព្រះសូត្រ បញ្ញាចាត់ចូលក្នុងអភិធម្មបិដក។ ដូច្នេះឃើញថា គ្មានធម៌ណាជាល្បោយធម៌ណាទេ តែងមានទំនាក់ទំនងគ្នា ជាសហជាតិធម៌ រួមគ្នាទើសម្រេចព្រះនិព្វាន។ បានសេចក្តីថា លោកុត្តរបញ្ញា បើខ្វះសីលសមាធិមិនអាចកើតឡើងបានឡើយ។ តួវិន័យជាផ្នែកសីលសម្រាប់កំចាត់បង់នូវទោសគ្រោតគ្រាតដែលប្រព្រឹត្តទៅតាមកាយនិងវាចា។ សមាធិសម្រាប់កំចាត់បង់នូវទោសឬកិលេសយ៉ាងកណ្តាល បានដល់នីវរណធម៌ទាំង៥ មានកាមច្ឆន្ទៈជាដើម ជាធម៌រារាំងផ្លូវចិត្ត មិនឲ្យចិត្តតាំងនៅក្នុងអារម្មណ៍តែមួយជាកុសល នេះផ្នែកប្រសូត្រ។ ព្រះអភិធម្មជាផ្នែកលោកុត្តរបញ្ញា ដឹងច្បាស់នូវត្រៃលក្ខណ៍ធម៌ ចាក់ធ្លុះនូវអរិយសច្ច៤ លះកិលេសយ៉ាងល្អិត ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន។

ព្រះសម្ពុទ្ធសំដែងធម៌ សុទ្ធតែជាធម៌ពិតហើយមានប្រយោជន៍ដល់សត្វយកទៅប្រតិបត្តិតាម ដើម្បីចេញចាកទុក្ខ ពុំមែនសំដែងធម៌ឥតប្រយោជន៍ជាល្បោយ ដូចគណបក្សមួយនោះពោលឡើយ។ ធម៌រាក់ស្រណុកយល់ ធម៌ជ្រៅពិបាកយល់ សុទ្ធតែជាធម៌សម្រាប់កំចាត់កិលេសតណ្ហា ដែលប្រព្រឹត្តទៅក្នុងកាយវាចាចិត្ត ប្រៀបដូចថ្នាំសម្រាប់រម្ងាប់រោគផ្លូវកាយ គេប្រើថ្នាំតាមប្រភេទរបស់រោគ ដូចជារោគឬកិលេសផ្លូវចិត្ត ព្រះពុទ្ធបានសំដែងធម៌រាក់ជ្រៅយកទៅរម្ងាប់កិលេសតាមប្រភេទរបស់កិលេស ដូចគ្នាដែរ។ ធម៌មានជម្រៅដូចជាអភិធម្ម ក៏ជាដៃគូជាមួយធម៌ដទៃទៀតដើម្បីរំដោះទុក្ខ។ ដូចមគ្គប្រកបដោយអង្គ៨ សម្មាវាចា សម្មាអាជីវោ សម្មាកម្មន្តោ ចាត់ចូលជាផ្នែកសីល សម្មាសតិ សម្មាវាយាមោ សម្មាសមាធិ ផ្នែកសមាធិ សម្មាទិដ្ឋ សម្មាសង្កប្បោ ផ្នែកបញ្ញា។

ដូច្នេះ អ្នកពោលធម៌ ត្រូវស្រាវជ្រាវឲ្យយល់ច្បាស់ មុននឹងសំដែងប្រាប់គេ ព្រោះបើនិយាយខុស គេស្តាប់ខុស យកទៅប្រតិបត្តិខុស នាំឲ្យខូចតម្លៃព្រះពុទ្ធសាសនា។ គេមិនអាចប្រឡងតែម្នាក់ឯង ជាប់លេខមួយតែម្នាក់ឯង ថាជាជើងឯកឡើយ។

វត្តខ្មែរកាណាដា,ថ្ងៃ២៧វិច្ឆិកា២០១៦;www.hoksavann.org;savannhok@yahoo.com


## ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**

# ការិយាល័យច្បាប់
## រ៉ូសា & តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា





Andrew ´Bunna´ Taing, Esq.
មេធាវី តាំង ប៊ុណ្ណា

**ខ្ញុំនិយាយភាសារបស់អ្នក**

**Rosa & Taing Law, LLC**

Serving our community in your language

- Auto Accidents/ Personal Injury • គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- Real Estate Closings Home-Lands • កាត់ឈ្មោះផ្ទះ និងដី
- Bankruptcy • ក្ស័យធន
- Immigration • អន្តោប្រវេសន៍
- Divorces & Child Custody • លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com



# ជ្រើសរើសបុគ្គលិក

**កាសែតខ្មែរផុសស.រ.អាត្រូវការជ្រើសរើសបុគ្គលិកផ្នែក**
**លក់ពាណិជ្ជកម្ម ចំនួន២នាក់**

បេក្ខជនត្រូវមានលក្ខណៈដូចខាងក្រោម :

-រៀននៅមហាវិទ្យាល័យយ៉ាងហោចឆ្នាំទី៣
-មានជំនាញខាងផ្នែក Business ឬ Marketing
-ត្រូវចេះប្រាស្រ័យជាមួយភ្ញៀវពាណិជ្ជកម្មតាមប្រព័ន្ធទូរស័ព្ទ និងជួបផ្ទាល់
-( ត្រូវចេះ Typing), សរសេរ E-mail ប្រើ Internet និង Facebook
( បើចេះWebsiteកាន់តែល្អ )
-ត្រូវចេះធ្វើការជាមួយសហការីនៅក្នុង Office
-ត្រូវចេះនិយាយ សរសេរភាសាខ្មែរ និងអង់គ្លេស
-ត្រូវការមួយអាទិត្យ១៥ម៉ោង
-ត្រូវមាន License បើកបរ និងរថយន្ត
- Pay មួយម៉ោង $9.30 បូកនឹងរង្វាន់

**សូមទាក់ទងមក ស្វជាតិ ចាន់ info@khmerpost.us**





# តម្រឹមធ្មេញដោយមិនយកថ្លៃ

ប្រសិនបើលោកអ្នកឬគ្រួសារ មានអាយុ២១ឆ្នាំ ឬក្មេងជាង សូមទូរស័ព្ទមកយើងនៅថ្ងៃនេះ ដើម្បីរកមើលថាតើលោកអ្នកមានសិទ្ធិនឹងទទួលបាននូវ "ប្រដាប់តម្រឹមធ្មេញ"ដោយ មិនចំណាយប្រាក់ ឬទេនៅពេលលោកអ្នកមាន"ម៉ាសហែល"? លោកអ្នកអាចនឹងទទួលសំណងរហូតដល់៤,៣០០ដុល្លា សម្រាប់ដាក់"ប្រដាប់តម្រឹមធ្មេញ"ទៅតាមសេចក្ដីត្រូវការរបស់អ្នក។

The **BRACES** PLACE

វេជ្ជបណ្ឌិត មូហាប់ វីសកាឡា DDS MSD



## តើយើងធ្វើអ្វីខ្លះ?

ដាក់ធ្មេញដោយដែក * ដោយមាស * ដោយ"អិនវីសាឡាញ" * ដោយចាន

## អ្វីដែលធ្វើឱ្យយើងប្រសើរបាននោះ?

- ឆ្លុះមើលបន្ថែម នឹង ជួបគ្រូពេទ្យ
- យើងទទួលយក"ម៉ាសហែល" នឹង "អិនស្វូរិន"ផ្សេងៗទៀត
- បង់ប្រាក់កក់មុនតិចបំផុត នឹងមានវិធីបង់ប្រាក់រំលោះប្រចាំខែសម្រាប់អ្នកដែលគ្មាន"អិនស្វូរិន" សូមទូរស័ព្ទ ឬក៏មកកន្លែងដែលស្រួលរករបស់យើង

710 Chelmsford St. Lowell, MA 01851
**(978)- 454 - 0774** (មានអ្នកនិយាយភាសាខ្មែរ)
ដើម្បីបានព័ត៌មានបន្ថែម, សូមចូលទៅ"វេបសាយ"យើង: www.bracesplaces.com

# របៀបធ្វើ គៀវចៀន









**គ្រឿងផ្សំស្លុល:**

-ពងមាន់ ១-១០០ក្រាម សាច់ជ្រូកចិញ្ច្រាំ-១០០ក្រាម បង្គាស្រស់ ហាន់ល្អិត១-ប៉ិតក់ ដើមខ្ទឹម ទំពាំងព្រេច ស្លៃក្តោប ផ្សិតចំបើង (គ្រឿងបន្លែ ត្រូវហាន់ល្អិត១គ្រប់មុខចំនួនរង្វាល់ខ្នាត មួយស្លាបព្រាធំ ស្មើគ្នា)

-ម្សៅឈូក ១ស្លាបព្រាកាហ្វេ(ដាក់ម្សៅមី ឬម្សៅឆា បើអត់ម្សៅឈូក)

-អំបិល ចុងស្លាបព្រាកាហ្វេ-ម្រេច កន្លះស្លាបព្រាកាហ្វេ-ស្ករកន្លះស្លាបព្រាកាហ្វេ-ប្រេងល្ង ១ស្លាបព្រា- សំបកក្រៅ បន្ទះម្សៅមី

**វិធីធ្វើ:**

១- លាយគ្រឿងនិងសាច់បញ្ចូលគ្នា ។

២- ខ្ចប់ហើយបំពងខ្លាញ់ អោយស្រួយ ។

៣- ស្ងោរអោយឆ្អិនស្រង់មក ស្រូបទឹកស៊ុបមីគៀវ ថែមគ្រឿងគ្រៅតាមចំណូលចិត្ត ។




CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ

- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ

- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វើកខឹខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង



Red Rose
ភោជនីយដ្ឋាន RESTAURANT
កុលាបក្រហម ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm












*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400



**KhmerPost USA, LLC**
**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

**ផ្សាយពាណិជ្ជកម្ម Advertising**
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

**អ្នកនិពន្ធ Editorials**
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Contributing Writers:**
Kayla Chan, Richard Howe Jr, Photographer/Videographer: Ra Yin
**ច្នៃសោភ័ណភាពកាសែត Design Artist**
Heng Chhunleng
**ជំនួយការរដ្ឋបាល** Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

# បើកទំព័រថ្មីសម្រាប់ទទួលយោបល់លោកអ្នកអាន

ដើម្បីចូលរួមស្វាគមន៍ឆ្នាំ២០១៧, យើងមានសេចក្តីរីករាយនឹងបើកទំព័រថ្មីម្រាប់ទទួលផ្សាយដោយសេរីនូវគំនិតយោបល់នឹងព័តិមានផ្សេងៗដែលលោកអ្នកអានមានបំណងធ្វើការផ្សព្វផ្សាយជាសាធារណៈនៅរៀងរាល់ពេលដែលយើងទទួលបាននូវអត្ថបទថ្មីពីលោកអ្នក។

សូមផ្ញើរអត្ថបទ រូបថត ឬ រូបគំនូរ មក info@khmerpost.us សម្រាប់អ្នកដែលចេះប្រើ "អាំងទែណេត" ឬក៏ផ្ញើរមកអស័យដ្ឋាន Khmerpost U.S.A. Editorial
45, Merrimack Street, #218A
Lowell, Lowell MA 01852_USA
សូមសរសេរដោយដៃក្នុងចន្លោះខាងក្រោមនេះរួចកាត់ផ្ញើរមកយើងខ្ញុំ

យើងជឿជាក់ថា គំនិត យោបល់ នឹងព័តិមានពីលោកអ្នកនឹងជួយជាប្រយោជន៍ដល់សហគមន៏ញាតិមិត្ត ក្រុមគ្រួសារជាមិនខាន។ សូមកុំភ្លេចដាក់ឈ្មោះ ឬដាក់រូបថត សម្រាប់សំគាល់ម្ចាស់អត្ថបទផង។ **-សូមអរគុណ-**






( អស័យដ្ឋានអ្នកផ្ញើរ )

បិតតែម

Khmerpost U.S.A., Editorial Dep.
45, Merrimack Street, #218A
Lowell, Lowell MA 01852_
USA

បត់ជា២....................................................................................................................................

**អត្ថបទក្នុងសំបុត្រនេះ:**
**១-** ជាអត្ថបទ ឬ ព័ត៌មាន សុំឱ្យចុះផ្សាយ
**២-** ជាសំនួរ សុំឱ្យឆ្លើយតាមទំព័រកាសែត
**៣-** ជាសំនួរ សុំឱ្យឆ្លើយតប មិនឱ្យផ្សាយទេ
សំបុត្រនេះអាចបត់ជាពីរ បិទការខាង២ បិតតែមមួយ រួចផ្ញើរមកយើងតាមប៉ុស្តិ៍
- សូមគូសនៅ ១-២ ឬ ៣ ដែលត្រូវនឹងសំបុត្រនេះ


# MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ**
**មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

**www.marcottelawfirm.com**



fallonhealth

**រកអ្នកធ្វើការ ចេះភាសាខ្មែរ តំណាងសហគមន៍ខរ័ធំសុខភាព តំបន់ឡូវែល**
Sr. Care (SCO) Community Representative Lowell Area – Khmer Language a must

**ណេវីឃែរ** (Navicare)**ជាអ្វី:**
ហ្វាលលនហែល (Fallon Health) គឺជាអ្នកផ្តល់ដំណោះស្រាយដឹកមុខគេ ខាងផ្នែករក្សាសុខភាពមនុស្សចាស់, ដូចជា ណេវីឃែរ ដែរ ដែលផ្តល់ផលចំណេញ មែឌីឃែរល្អ (Medicare Advantage), ផែនការតម្រូវការពិសេស (Special Needs Plan) នឹងជម្រើសកម្មវិធីថែទាំមនុស្សចាស់ (Senior Care Option)។ ណេវីឃែ្ក មានបញ្ចូលការថែទាំមនុស្សពេញវ័យ ចាប់ពីអាយុ៦៥ឆ្នាំ នឹងច្រើនជាងដែលមានសិទ្ធិ២យ៉ាង ទទួលមេឌីឃែ្ក (Medicare) ផង នឹងប័ណ្ណធានាសុខភាពម៉ាសាឈូសិតស្តង់ដា (Mass Health) ផង។ ក្រុមអ្នកថែទាំមបមផ្ទាល់ខ្លួន គ្រប់គ្រងនឹងទាក់ទង សមាជិកថែរសុខភាព ណេវីឃែ្ក ដោយធ្វើការជាមួយសមាជិកម្នាក់ៗ, សមាជិកនៃគ្រួសារ, នឹងអ្នកផ្តល់សេវាសុខភាព ដើម្បីធានាបាននូវលទ្ធផលល្អប្រសើរបំផុត។
តំណែងនេះត្រូវឱ្យ ទាក់ទងទៅខាងក្រៅ សម្រេចបំណងទទួលបាននូវភ្ញៀវផ្ទាល់ខ្លួន -លក់ផលិតផល -ទៅដល់គោលដៅដែលចេញទៅទាក់ទងគេសម្រាប់កម្មវិធីណេវីឃែ្ក។ គ្រប់គ្រងដែនតំបន់នឹងបញ្ជីគណនីដើមនៃក្រុមភ្ញៀវ, ផ្តល់នូវការតាមដានយ៉ាងទៀងទាត់ នឹងយកឈ្នះនូវរនាំងជាមួយករណីនិមួយៗ ដើម្បីឱ្យបានជាភ្ញៀវ។ យើងរង់ចាំអ្នកនៅតំបន់ឡូវែលនឹងចេះភាសាខ្មែរ។

**បទពិសោធន៍ :**
-មានបទពិសោធន៏ចាប់ពីព៣ឆ្នាំ នៅក្នុងមណ្ឌលសុខភាព ឬនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងដែលរឹងមាំណាមួយ
-មានបទពិសោធន៏ច្បាស់លាស់ក្នុងកិច្ចការអតិថិជន ប្រឈមមុខតួនាទីផ្នែកលក់ ជំនាន់អ្នកដឹកនាំជាន់ខ្ពស់ខាងសេវាអតិថិជន នឹងបរិដ្ឋាននៃការលក់
-មានចំណេះដឹងខាងសេវាមេឌីឃែ្ក (Medicare) ខាងមេដឌីខេដ ( Medicaid) នឹងផលិតផលធានារ៉ាប់រង កាន់តែប្រសើរ
-មានប័ណ្ណបើកបរនៅរដ្ឋម៉ាសាឈូសិត អាខប្រើបាន នឹងមានរថយន្តសម្រាប់ការងារទីផ្សារ ការងារទៅជួបភ្ញៀវដល់ផ្ទះ

សូមទាក់ទងមក:
Lisa RosenKrantz
Sr. Recruiter Talent Acquisition Fallon Health
Lisa.rosenkrantz@fallonhealth.org
**508-368-9663**

# Read us online at www.khmerpost.us

KhmerPost USA is the only Cambodian newspaper that has the highest circulation and is most read in the Cambodian communities in the Greater Merrimack Valley, Boston and beyond. It provides important news and information to a market that is often isolated from the larger community due to a language barrier. This includes the national and international news, and the practical local information concerning health, education, politics, businesses and community involvement.

**Publication Frequency**

24 times a year. Prints on every other Friday

**General Information**

Circulations: 10,000 free copies per month

Distributions:

- 60 locations in Lowell, MA (3,000 copies per issue)
- 25 Locations in Lynn and Revere, MA (500 copies per issue)
- 25 Locations in Cranston & Providence, RI (1,000 copies per Issue)

**2016 & 2017 Publication Dates**

- December 2nd & 16th, 2016
- January 6th & 20th, 2017
- February 3rd & 17th, 2017
- March 10th & 24th, 2017
- April 7th & 21st , 2017
- May 5th & 19th, 2017
- June 9th, & 23rd, 2017
- July 7th & 21st, 2017
- August 4th & 9th, 2017
- September 8th & 22nd, 2017
- October 6th & 20th, 2017
- November 3rd & 17th, 2017
- December 8th & 22nd , 2017

* all ad materials are due one due one week prior to the publishing date.

**Advertising Rates**

| Ad Size | 1 issue | 3 month 5% off | 6 month 7.5% off | 12 month 10% off |
|---|---|---|---|---|
| full | 460.00 | 2,622.00 | 5,106.00 | 9,936.00 |
| 1/2 | 310.00 | 1,674.00 | 3,441.00 | 6,696.00 |
| 1/4 | 165.00 | 940.50 | 1,831.50 | 3,564.00 |
| 1/8 | 90.00 | 513.00 | 999.00 | 1,944.00 |




**Ads Sizes & Dimensions**

| | |
|---|---|
| 1 Full page inside | (13"x10") |
| 1/2 page color | (6.5"x10") |
| 1/4 page color | (6.5"x5") |
| 1/8 page color | (3.25"x5") |

**Office:** 45 Merrimack Street. Suite 218A. Lowell, MA 01852

**Tel:** 978.677.7163. **Cell:** 978. 656.8141. Fax: 978.677.7092

Email: sobenpin@khmerpost.us | www.khmerpost.us

**New ! We accept credit Cards :** VISA MasterCard AMERICAN EXPRESS

Schedules and Rate revision and effective September 1st, 2015



# រមណីដ្ឋានទឹកធ្លាក់ល្បាក់ខោន ( ឬ សុភមិត្រ )





កុមារកម្ពុជាដែលបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៩នឹងបានស្គាល់ទីតាំងភូមិសាស្ត្រនេះយ៉ាងច្បាស់ គឺទឹកជ្រោះល្បាក់ខោនស្ថិតនៅភាគខាងជើងប្រទេសកម្ពុជា។ ពួកគេដឹងថា នេះគឺជាតំបន់មួយដែលទន្លេមេគង្គហូរឆ្លងកាត់ចុះមកមានកំពស់២៦មចេញពីខ្ពង់រាបជាប់ព្រំដែនប្រទេសកម្ពុជានិងសាធារណរដ្ឋឡាវ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏មនុស្សភាគច្រើនប្រហែលជាមិនសូវបានទៅទស្សនានៅតំបន់នោះទេ។

នៅក្នុងរដូវភ្លៀងនៅពេលដែលទឹកទន្លេចាប់ផ្តើមឡើងពេញប្រៀបមាត់ច្រាំងដោយទំហំទឹកធំ និងល្បឿនកាន់តែខ្លាំងនោះបានបង្កើតឱ្យមានទស្សនីយភាពកាន់តែស្រស់ស្អាត គួរជាទីគយគន់ជាមួយផ្សែងអ័ព្ទដែលបានផុសចេញពីទឹកដែលកំពុងធ្លាក់។ ចំណែកឯនៅក្នុងរដូវប្រាំងវិញ ទឹកក៏ចាប់ផ្តើមចុះស្រកបាននាំឱ្យទីនេះលេចចេញនូវទេសភាពល្អត្រកាលប្រែក្លាយជាវាលដែលរំលេច ដោយថ្មពណ៌ក្រហម ខ្មៅ និងស ។ តែភ្ញៀវទេសចរដែលបានទៅលេងនៅទីនោះក៏ត្រូវប្រយ័ត្ននឹងដុំថ្មស្រួចៗរដិបរដុបដែលនៅទីនោះផងដែរ។

ចំណែកលោក កាំ ពួយបាននិយាយថា ខាងពីមុនទីនេះពុំសូវមានភ្ញៀវទេសចរមកទស្សនាទេ ពីព្រោះការធ្វើដំណើរតាមទូកបានជួបការលំបាកដោយត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារបុកនឹងរបាំងថ្មធំៗដែលនៅក្នុងទន្លេ។

ដូចគ្នានេះដែរ អ្នកស្រុករស់នៅតំបន់នេះបាននិយាយថា ភ្ញៀវទេសចរមិនហ៊ានជិះទូកមកទីនេះទេ ព្រោះខ្លាចបុកនឹងរបាំងថ្ម និងខ្លាចទឹកដែលមានល្បឿនខ្លាំងនៅទីនេះកួចយកទៅ ហើយមានតែអ្នកដែលរស់នៅទីនេះ ដែលដឹងពីល្បឿនទឹក និងស្ថានភាពផ្លូវទឹកច្បាស់ដែលអាចធ្វើដំណើរមកទីនេះបាន។



នៅពេលថ្មីៗនេះ ក៏មានក្រុមទេសចរបានចាប់ផ្តើមធ្វើដំណើរមកកំសាន្តនៅរមណីដ្ឋានទឹកធ្លាក់ល្បាក់ខោននេះដែរ ហើយពួកគេមួយចំនួនជាភ្ញៀវទេសចរ ហើយបានស្លៀកសំលៀកបំពាក់ការពារសុវត្ថិភាពនៅពេលដែលពួកគេធ្វើដំណើរតាមទូកមកទស្សនានៅទីនោះ។

លោក កាំ ពួយ បាននិយាយបន្តទៀតថា "ទោះបីជាយ៉ាងណាក៏ដោយពួកគេហាក់ដូចជាពេញចិត្តនឹងការធ្វើដំណើរថ្មើជើងនៅជុំវិញបរិវេណទឹកធ្លាក់ជាងការធ្វើដំណើរដោយទូក ។ ពីព្រោះថា នៅរដូវប្រាំងទឹកចាប់ផ្តើមស្រកហើយកំលាំងទឹកខ្សោយ ។ ចំណែកនៅរដូវវស្សាវិញ ទឹកមានទំហំធំទឹកកួចមានល្បឿនខ្លាំង និងហូរលឿនដែលនាំឱ្យទូកពិបាកឆ្លងកាត់ ។ "ហើយគាត់បន្តទៀតថា " នៅរដូវណាក៏ដោយក៏ធ្លាក់នៅទីនេះប្រកបដោយសភាពគ្រោះថ្នាក់ជានិច្ច" ។

អ៊ុំកាំ ពួយបានរស់នៅក្នុងភូមិ អន្លង់ស្វាយ ឃុំ ព្រះរុំកិល ស្រុកថាឡាបូរីវ៉ាត់ ខេត្តស្ទឹងត្រែង ។ គាត់បាននិយាយថា ទីនេះសម្បូរត្រីខ្លាំងណាស់នៅពេលទឹកធ្លាក់។ ទឹកធ្លាក់ល្បាក់ខោន ឬទឹកធ្លាក់សុភមិត្រ គឺជាតំបន់មួយដែលទឹកទន្លេមេគង្គហូរឆ្លងកាត់ ហើយស្ថិតនៅក្នុងឃុំ ព្រះរំកិល ស្រុកថាឡាបូរីវ៉ាត់ ខេត្តស្ទឹងត្រែង និងស្ថិតក្នុងភូមិ កំពង់ស្រឡៅ ស្រុកឆែប ខេត្តព្រះវិហារ នៃព្រះរាជាណាចក្រកម្ពុជា៕